មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTRE

# បទបញ្ជាផ្ទៃក្នុង

២៨ មីនា ២០២១

# មាតិកា


**បុព្វកថា** ១

ជំពូកទី ១

**បទប្បញ្ញត្តិទូទៅ** ២

ប្រការ ១. ឈ្មោះ និងទម្រង់គតិយុត្ត ២

ប្រការ ២. ទីស្នាក់ការរបស់ ម.ជ.ម. ២

ប្រការ ៣. គោលបំណង ២

ប្រការ ៤. ការបកស្រាយ ៣

ប្រការ ៥. ការទាក់ទង ៣

ប្រការ ៦. ពេលវេលាកំណត់ ៣

ប្រការ ៧. វិធានបន្ថែម ៤

ជំពូកទី ២

**អគ្គលេខាធិការ និងអគ្គលេខាធិការដ្ឋាន** ៥

ប្រការ ៨. អគ្គលេខាធិការ ៥

ប្រការ ៩. អគ្គលេខាធិការដ្ឋាន ៦

ប្រការ ១០. អ្នកបម្រើការងាររបស់ ម.ជ.ម. ៧

ជំពូកទី ៣

**សមាជិកភាពរបស់ ម.ជ.ម.** ៨

ប្រការ ១១. សមាជិករបស់ ម.ជ.ម. ៨

ប្រការ ១២. លក្ខណសម្បត្តិ និងការចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកមជ្ឈត្តករ ៨

ប្រការ ១៣. លក្ខណសម្បត្តិ និងការចុះបញ្ជីនីតិបុគ្គលជាសមាជិកជានីតិបុគ្គល ១២

ប្រការ ១៤. លក្ខណសម្បត្តិ និងការចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកគាំទ្រជារូបវន្តបុគ្គល ១៦

ប្រការ ១៥. លក្ខណសម្បត្តិ និងការចុះបញ្ជីនីតិបុគ្គលជាសមាជិកគាំទ្រជានីតិបុគ្គល ១៨

ប្រការ ១៦. ការអនុគ្រោះពេលវេលាកំណត់ ២០

ប្រការ ១៧. ភាគទាន ២១

ប្រការ ១៨. ទិន្នន័យ និងបញ្ជីផ្សេងៗ ២១

ប្រការ ១៩. ការបញ្ចប់សមាជិកភាព ២១

ប្រការ ២០. នីតិវិធីនៃការបញ្ចប់សមាជិកភាព ២៣

ប្រការ ២១. អានុភាពនៃការមិនបន្តសារជាថ្មី និងការបញ្ចប់សមាជិកភាព ២៣

ប្រការ ២២. ការដកហូតអ្នកតំណាង ២៤

ជំពូកទី ៤

## មហាសន្និបាត ២៥

ប្រការ ២៣. សមត្ថកិច្ចរបស់មហាសន្និបាត ២៥

ប្រការ ២៤. កិច្ចប្រជុំរបស់មហាសន្និបាត ២៦

ជំពូកទី ៥

## ក្រុមប្រឹក្សាប្រតិបត្តិ ៣០

ប្រការ ២៥. ក្រុមប្រឹក្សាប្រតិបត្តិ និងសមត្ថកិច្ច ៣០

ប្រការ ២៦. ចំនួនសមាជិក និងសមាសភាពក្រុមប្រឹក្សាប្រតិបត្តិ ៣១

ប្រការ ២៧. ការទូទាត់សងការចំណាយ និងប្រាក់ឧបត្ថម្ភ ៣១

ប្រការ ២៨. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ ៣២

ប្រការ ២៩. ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ៣៤

ប្រការ ៣០. ការបញ្ចប់សមាជិកភាពនៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ៣៧

ប្រការ ៣១. អាណត្តិ និងការបោះឆ្នោត ៣៨

ជំពូកទី ៦

## គណៈកម្មាធិការ ៤០

ប្រការ ៣២. សមត្ថកិច្ចក្នុងការបង្កើតគណៈកម្មាធិការ ៤០

ប្រការ ៣៣. បទប្បញ្ញត្តិទូទៅសម្រាប់គណៈកម្មាធិការ ៤០

ប្រការ ៣៤. ការបង្កើត និងតួនាទីរបស់គណៈកម្មាធិការ ៤២

ជំពូកទី ៧

**ការរក្សាការសម្ងាត់របស់ ម.ជ.ម. ៤៤**

ប្រការ ៣៥. កាតព្វកិច្ចរក្សាការសម្ងាត់ ៤៤

ប្រការ ៣៦. បុគ្គលចូលរួមក្នុងកិច្ចការ និងសកម្មភាពរបស់ ម.ជ.ម. ៤៤

ជំពូកទី ៨

**ក្រុមប្រឹក្សាពិគ្រោះយោបល់ ៤៥**

ប្រការ ៣៧. ក្រុមប្រឹក្សាពិគ្រោះយោបល់ គោលបំណង និងតួនាទី ៤៥

ប្រការ ៣៨. សមាជិកភាព និងកិច្ចប្រជុំ ៤៥

ជំពូកទី ៩

**ការទទួលស្គាល់ស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស ៤៧**

ប្រការ ៣៩. ស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស ៤៧

ជំពូកទី ១០

**សមត្ថកិច្ចក្នុងការតំណាង ម.ជ.ម. ៤៨**

ប្រការ ៤០. សមត្ថកិច្ចក្នុងការតំណាង និងការចងកាតព្វកិច្ចចំពោះ ម.ជ.ម. ៤៨

ជំពូកទី ១១

**ការិយបរិច្ឆេទ និងសវនកម្ម ៥០**

ប្រការ ៤១. ការិយបរិច្ឆេទ គម្រោងថវិកា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍គ្រប់គ្រងប្រចាំឆ្នាំ ៥០

ប្រការ ៤២. សវនកម្ម ៥១

ជំពូកទី ១២

**អវសានប្បញ្ញត្តិ ៥២**

ប្រការ ៤៣. អវសានប្បញ្ញត្តិ ៥២

# បុព្វកថា

ក. **ដោយហេតុថា** ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដូចមានចែងក្នុងជំពូកទី ១) អនុក្រឹត្យលេខ ១២៤ (ដូចមានចែងក្នុងជំពូកទី ១) និងអនុក្រឹត្យលេខ ១៨២ ស្តីពីវិសោធនកម្មមាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ (ដូចមានចែងក្នុងជំពូកទី ១) បានបង្កើត ម.ជ.ម. (ដូចមានចែងក្នុងជំពូកទី ១) ឯករាជ្យ សម្រាប់គាំទ្រដល់ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការ ដើម្បីបង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់រៀបចំដំណើរការមជ្ឈត្តការលើសំណុំរឿងវិវាទពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ. **ដោយហេតុថា** បទបញ្ជាផ្ទៃក្នុងមានសារៈសំខាន់ក្នុងការគ្រប់គ្រងរចនាសម្ព័ន្ធ ដំណើរការ និងអភិបាលកិច្ចនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**ដូច្នេះ យើងខ្ញុំទាំងអស់គ្នា**ជាសមាជិករបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានព្រមព្រៀងគ្នាបង្កើត និងអនុវត្តតាមវិធានដូចមានកំណត់ក្នុងប្រការនានានៃបទបញ្ជាផ្ទៃក្នុងដូចមានចែងខាងក្រោមនេះ ដែលតទៅនេះហៅថា "បទបញ្ជាផ្ទៃក្នុង"។

## ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

### ប្រការ ១. ឈ្មោះ និងទម្រង់គតិយុត្ត

មជ្ឈមណ្ឌលមជ្ឈត្តការមានឈ្មោះថា មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហៅកាត់ថា "ម.ជ.ម." ។ ម.ជ.ម. គឺជានីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ហៅកាត់ថា "ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម" អនុក្រឹត្យលេខ ១២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ហៅកាត់ថា "អនុក្រឹត្យលេខ ១២៤" និងអនុក្រឹត្យលេខ ១៨២ ស្តីពីវិសោធនកម្មមាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ហៅកាត់ថា "អនុក្រឹត្យលេខ ១៨២" ។

### ប្រការ ២. ទីស្នាក់ការរបស់ ម.ជ.ម.

ម.ជ.ម. មានទីស្នាក់ការនៅរាជធានីភ្នំពេញ តាមអាសយដ្ឋានដែលបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

### ប្រការ ៣. គោលបំណង

បទបញ្ជាផ្ទៃក្នុងនេះ បំពេញបន្ថែម និងអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អនុក្រឹត្យលេខ ១២៤ និងអនុក្រឹត្យលេខ ១៨២។ បទបញ្ជាផ្ទៃក្នុងនេះមានគោលបំណងកំណត់ឱ្យបានច្បាស់លាស់អំពីរចនាសម្ព័ន្ធ នីតិវិធីសម្រាប់ប្រតិបត្តិការ និងរដ្ឋបាល និងអភិបាលកិច្ចរបស់ ម.ជ.ម.។

## ប្រការ ៤. ការបកស្រាយ

៤.១. សមាជិករបស់ ម.ជ.ម. អាចស្នើសុំឱ្យក្រុមប្រឹក្សាប្រតិបត្តិធ្វើការបកស្រាយប្រការណាមួយនៃបទបញ្ជាផ្ទៃក្នុងនេះ។

៤.២. បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម អនុក្រឹត្យលេខ ១២៤ និងអនុក្រឹត្យលេខ ១៨២។

## ប្រការ ៥. ការទាក់ទង

ក្នុងករណីដែលបទបញ្ជាផ្ទៃក្នុងនេះ តម្រូវឱ្យមានការទាក់ទងណាមួយ រួមទាំងការប្រគល់ឯកសារ ឬការជូនដំណឹងជាដើម ធ្វើឡើងជាលាយលក្ខណ៍អក្សរ ការទាក់ទងជាលាយលក្ខណ៍អក្សរនោះ ត្រូវប្រគល់តាមរយៈការប្រគល់ដោយផ្ទាល់ដៃ ប្រៃសណីយ៍ ការបញ្ជូន សារអេឡិចត្រូនិច ឬមធ្យោបាយទាក់ទងផ្សេងទៀត ដែលមានកំណត់ត្រាអំពីការប្រគល់នោះ។

ការទាក់ទងនឹងត្រូវចាត់ទុកថាបានទទួល ប្រសិនបើការទាក់ទងនោះត្រូវបានបញ្ជូន និងប្រគល់ទៅអ្នកត្រូវទទួល ឬទៅអ្នកតំណាងរបស់អ្នកត្រូវទទួល ដូចក្នុងករណីណាមួយខាងក្រោម៖

(ក) ត្រូវបានទទួលដោយផ្ទាល់ ឬត្រូវបានបញ្ជូន និងប្រគល់នៅលំនៅឋាន ឬទីស្នាក់ការ ឬអាសយដ្ឋានសារអេឡិចត្រូនិច ឬអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ដែលអ្នកត្រូវទទួលបានកំណត់

(ខ) ក្នុងករណីដែលគ្មានព័ត៌មានអំពីអាសយដ្ឋានក្នុងចំណុច (ក) ខាងលើនេះ ការទាក់ទងជាលាយលក្ខណ៍អក្សរនោះត្រូវបានទុកនៅទីសំណាក់ ឬកន្លែងអាជីវកម្មចម្បងរបស់អ្នកត្រូវទទួល ឬ

(គ) ក្រោយពីការស្វែងរកតាមមធ្យោបាយដែលសមហេតុផលហើយ ប្រសិនបើមិនអាចកំណត់ចំណុចណាមួយខាងលើទេនោះ ការទាក់ទងជាលាយលក្ខណ៍អក្សរនោះត្រូវបានបញ្ជូន និងប្រគល់នៅលំនៅឋានរបស់អ្នកតំណាង ឬអាសយដ្ឋានសារអេឡិចត្រូនិចចុងក្រោយរបស់អ្នកត្រូវទទួល។

## ប្រការ ៦. ពេលវេលាកំណត់

អំឡុងពេលណាមួយដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលការទាក់ទងណាមួយត្រូវបានទទួលស្របតាមប្រការ ៥ ខាងលើ។ ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលនោះគឺជាថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាករបស់ស្ថាប័នសាធារណៈ តាមការកំណត់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អំឡុងពេលនោះនឹងត្រូវពន្យាររហូតដល់ថ្ងៃធ្វើការទីមួយ បន្ទាប់ពីថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាករបស់ស្ថាប័នសាធារណៈ តាមការកំណត់ដោយរាជរដ្ឋាភិបាល

នៃព្រះរាជាណាចក្រកម្ពុជានោះ។ ការគណនាអំឡុងពេលនោះត្រូវរាប់បញ្ចូលផង ដែរនូវថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកបស់ស្ថាប័នសាធារណៈ តាមការកំណត់ ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៧. វិធានបន្ថែម

ក្រុមប្រឹក្សាប្រតិបត្តិ ផ្អែកតាមភាពចាំបាច់ ឬសារៈប្រយោជន៍ អាចកំណត់វិធានបន្ថែម ពាក់ព័ន្ធនឹងរដ្ឋបាល ហិរញ្ញវត្ថុ ធនធានមនុស្ស ឬកិច្ចការផ្សេងទៀតបាន ដោយ វិធានទាំងនោះត្រូវបង្កើតឡើងឱ្យស្របតាមបទបញ្ជាផ្ទៃក្នុងនេះ ព្រមទាំងសេចក្តី សម្រេចនានាដែលបានអនុម័តដោយមហាសន្និបាត។

ជំពូកទី ២

# អគ្គលេខាធិការ និងអគ្គលេខាធិការដ្ឋាន

## ប្រការ ៨. អគ្គលេខាធិការ

៨.១. អគ្គលេខាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាប្រតិបត្តិ និងត្រូវទទួលខុសត្រូវចំពោះក្រុមប្រឹក្សាប្រតិបត្តិ។ តួនាទីរបស់អគ្គលេខាធិការត្រូវឯករាជ្យពីសកម្មភាព ឬការងាររបស់មជ្ឈត្តករជាទូទៅ ទោះបីជាសកម្មភាព ឬការងារនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស។ ដើម្បីជៀសវាងការភ័ន្តច្រឡំ នៅពេលកំពុងបំពេញតួនាទីជាអគ្គលេខាធិការ អគ្គលេខាធិការមិនត្រូវធ្វើសកម្មភាព ឬចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងសកម្មភាពជាមជ្ឈត្តករ ឬបំពេញតួនាទីណាមួយក្នុងដំណើរការមជ្ឈត្តការឡើយ ទោះបីជានៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសក៏ដោយ។

៨.២. តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការ ត្រូវរួមបញ្ចូលទាំងតួនាទី និងភារកិច្ចណាមួយ ឬទាំងអស់ដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនេះ ឬវិធានផ្សេងៗ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវកំណត់អំពីលក្ខណសម្បត្តិរបស់អគ្គលេខាធិការ។

៨.៣. ពាក់ព័ន្ធនឹងការគ្រប់គ្រងអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. អគ្គលេខាធិការត្រូវធានាថា៖

(ក) ប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុរបស់ ម.ជ.ម. ត្រូវបានបង្កើតឡើងស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន

(ខ) ការជ្រើសរើសបុគ្គលិកសម្រាប់បម្រើការក្នុង ម.ជ.ម. ត្រូវបានធ្វើឡើងស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀត

(គ) សកម្មភាពសំខាន់ៗទាំងអស់របស់ម.ជ.ម.ដែលអាចមានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិយ៉ាងទៀងទាត់ និង

(ឃ) រាល់ការចំណាយទាំងអស់ និងកាតព្វកិច្ចណាមួយ ឬកិច្ចសន្យាណាមួយ ដែលបានធ្វើដោយម.ជ.ម. ត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន បទបញ្ជាផ្ទៃក្នុងនេះ និងតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការ។

៨.៤. ក្រុមប្រឹក្សាប្រតិបត្តិអាចដកអគ្គលេខាធិការចេញពីតួនាទី ដោយផ្អែកលើមូលហេតុណាមួយដូចខាងក្រោម៖

(ក) ការខកខានក្នុងការអនុវត្ត ការធ្វើតាម និងការសម្រេចគោលដៅ និងកម្មវត្ថុរបស់ ម.ជ.ម. ឬគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិបានដាក់ចេញ

(ខ) ធ្វើសកម្មភាព ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្បាប់ នយោបាយ ឬពាក់ព័ន្ធនឹងសង្គម ដែលអាចនាំឱ្យអាប់ឱន ឬប៉ះពាល់ដល់ភាពសុចរិតរបស់ ម.ជ.ម. និងត្រូវរាប់បញ្ចូលផងដែរនូវសកម្មភាពនានារបស់ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង ៣ (បី) ថ្នាក់ របស់អគ្គលេខាធិការ និងដៃគូពាណិជ្ជកម្មរបស់អគ្គលេខាធិការ

(គ) ការទទួលយកតំណែង ឬការតែងតាំង (ទោះបីជាក្នុងផ្នែកនយោបាយ ឬផ្នែកផ្សេងទៀត) កម្រៃ ឬឋានៈណាមួយ ដែលនាំឱ្យមានទស្សនៈខុសឆ្គង ឬដែលប៉ះពាល់ដល់តួនាទី និងសកម្មភាពរបស់អគ្គលេខាធិការ ឬភាពសុចរិតរបស់ ម.ជ.ម. ឬ

(ឃ) ការប្រព្រឹត្តកំហុសណាមួយរួមមានជាអាទិ៍ ការជាប់ពាក់ព័ន្ធនឹងការសូកប៉ាន់ អំពើពុករលួយ ការគៃបន្លំ កំហុសក្នុងការគ្រប់គ្រង ឬការប្រកាន់បក្សពួកនិយម។

## ប្រការ ៩. អគ្គលេខាធិការដ្ឋាន

ក្នុងចំណោមសកម្មភាពនានា អគ្គលេខាធិការដ្ឋានត្រូវបំពេញសកម្មភាពក្រោមការទទួលខុសត្រូវរបស់អគ្គលេខាធិការដូចខាងក្រោម៖

(ក) ការគ្រប់គ្រងសំណុំរឿងវិវាទ៖

ក.១-ធ្វើសកម្មភាពដែលតម្រូវដោយ និងស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. និង

ក.២-គ្រប់គ្រងកាលវិភាគនៃសំណុំរឿងវិវាទ និងដំណើរការឯកសារ ដែលត្រូវបានដាក់ជូន ឬដែលបានឆ្លើយឆ្លងគ្នាក្នុងដំណើរការមជ្ឈត្តការ

(ខ) រដ្ឋបាល និងហិរញ្ញវត្ថុ៖

ខ.១-កំណត់ និងប្រមូលកម្រៃសេវាចុះបញ្ជី កម្រៃសេវារដ្ឋបាល កម្រៃសេវាតែងតាំងមជ្ឈត្តករ កម្រៃសេវាផ្ទៃកាមជ្ឈត្តកម្មពីភាគីវិវាទ

ខ.២-រក្សាបញ្ជីឈ្មោះរបស់មជ្ឈត្តករ និងរបស់សមាជិកផ្សេងទៀតរបស់ ម.ជ.ម. និងធានាបច្ចុប្បន្នភាពនៃបញ្ជីទាំងនោះ

ខ.៣-រៀបចំធ្វើសេចក្តីព្រាងគម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងផែនការសកម្មភាពរបស់ ម.ជ.ម. សម្រាប់រយៈពេល ៣ (បី) ឆ្នាំ និង

ខ.៤-សកម្មភាពផ្សេងទៀត ដែលមានលក្ខណៈស្រដៀងគ្នានឹងកិច្ចការរដ្ឋបាល និងកិច្ចការហិរញ្ញវត្ថុជាទូទៅ

(គ) ទំនាក់ទំនងសាធារណៈ ការធ្វើទីផ្សារ និងការផ្សព្វផ្សាយជាសាធារណៈ

(ឃ) រៀបចំការអប់រំ និងបណ្តុះបណ្តាលដំបូង និងបន្តសម្រាប់មជ្ឈត្តករ

(ង) រៀបចំការអប់រំ និងបណ្តុះបណ្តាលសម្រាប់ភាគីពាក់ព័ន្ធ និងសាធារណៈជនទូទៅ

(ច) ថែរក្សា និងចងក្រងឯកសារ

(ឆ) ប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសកម្មភាពមជ្ឈត្តការ ដែលអាចមានប្រយោជន៍ដល់សមាជិក ម.ជ.ម.

(ជ) ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ និងរៀបចំសកម្មភាព និងគម្រោងនានា ដែលជួយទ្រទ្រង់តួនាទីរបស់ ម.ជ.ម.

(ឈ) ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ម.ជ.ម. ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ

(ញ) ទ្រទ្រង់ផ្នែកបោះពុម្ពផ្សាយនានារបស់ ម.ជ.ម. និងកាន់កាប់គេហទំព័ររបស់ ម.ជ.ម. និង

(ដ) បំពេញភារកិច្ចផ្សេងៗ ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

## ប្រការ ១០. អ្នកបម្រើការងាររបស់ ម.ជ.ម.

បុគ្គលគ្រប់រូប ដែលបម្រើការងារឱ្យ ម.ជ.ម. ក្នុងឋានៈជានិយោជិត ឬបុគ្គលជាប់កិច្ចសន្យា ឬជាទីប្រឹក្សា ត្រូវទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការលើការបំពេញការងាររបស់ខ្លួនក្នុង ម.ជ.ម.។

## ជំពូកទី ៣
# សមាជិកភាពរបស់ ម.ជ.ម.

### ប្រការ ១១. សមាជិករបស់ ម.ជ.ម.

សមាជិក ម.ជ.ម. រួមមាន៖

(ក) សមាជិកជាមជ្ឈត្តករ ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១២ ខាងក្រោម

(ខ) សមាជិកជានីតិបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៣ ខាងក្រោម

(គ) សមាជិកគាំទ្រជារូបវន្តបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៤ ខាងក្រោម និង

(ឃ) សមាជិកគាំទ្រជានីតិបុគ្គល ដែលមានលក្ខណសម្បត្តិ និងបានចុះបញ្ជីនៅ ម.ជ.ម. ស្របតាមប្រការ ១៥ ខាងក្រោម។

### ប្រការ ១២. លក្ខណសម្បត្តិ និងការចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកមជ្ឈត្តករ

១២.១.ដើម្បីចុះបញ្ជីជាសមាជិកជាមជ្ឈត្តករនៅ ម.ជ.ម. រូបវន្តបុគ្គលត្រូវមានលក្ខណសម្បត្តិទាំងអស់ដូចខាងក្រោម៖

(ក) មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ

(ខ) មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ដែលបញ្ចប់ពីមហាវិទ្យាល័យណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស

(គ) បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការ ដែលរៀបចំដោយ ម.ជ.ម. ឬវគ្គបណ្តុះបណ្តាលដែលរៀបចំដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម. និង

(ឃ) បានប្រឡងជាប់ការប្រឡងដែលរៀបចំដោយ ម.ជ.ម. ឬដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម.។

១២.២.ប្រសិនបើពុំមានលក្ខណសម្បត្តិទាំងអស់ដូចមានកំណត់ក្នុងប្រការ ១២.១ ទេនោះ រូបវន្តបុគ្គលអាចត្រូវបានចុះបញ្ជីជាសមាជិកជាមជ្ឈត្តករ ប្រសិនបើរូបវន្តបុគ្គលនោះមានលក្ខណសម្បត្តិណាមួយដូចខាងក្រោម៖

(ក) ធ្លាប់ជាសមាជិក ដែលបានចុះបញ្ជីត្រឹមត្រូវជាមជ្ឈត្តករយ៉ាងតិច ២ (ពីរ) ឆ្នាំ នៅស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ ដែលទទួលស្គាល់ដោយ ម.ជ.ម.

(ខ) ធ្លាប់ជាមជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី បី (៣) សំណុំរឿងវិវាទឡើងទៅ ឬបានសរសេរមជ្ឈត្តវិនិច្ឆ័យផ្នែកពាណិជ្ជកម្មចំនួនយ៉ាងតិច ៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ។ ចំពោះរូបវន្តបុគ្គល ដែលមានលក្ខណសម្បត្តិដូចមានកំណត់ក្នុងចំណុច (ខ) នេះ ត្រូវប្រឡងជាប់ការប្រឡង ដែលរៀបចំដោយ ម.ជ.ម. ឬដោយស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយដែលទទួលស្គាល់ដោយ ម.ជ.ម. ឬ

(គ) មានវិញ្ញាបនប័ត្រចុះបញ្ជីជាមជ្ឈត្តករនៅ ម.ជ.ម. និងបានរក្សាសមាជិកភាពជាមជ្ឈត្តករនៅ ម.ជ.ម. យ៉ាងតិចណាស់ ២ (ពីរ) ឆ្នាំ ជាប់គ្នាគិតពីថ្ងៃចុះបញ្ជី។

១២.៣.ក្រោយពីមានការយល់ព្រមពីមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់នូវលក្ខណសម្បត្តិបន្ថែមផ្សេងទៀត ដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាសមស្រប និងមានប្រយោជន៍ដល់ ម.ជ.ម. ។

១២.៤.សមាជិកជាមជ្ឈត្តករមិនត្រូវ៖

(ក) ជាមន្ត្រីរាជការ ឬស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ ឬតុលាការ។

(ខ) មានករណីណាមួយដែលបានកំណត់ក្នុងប្រការ ១៩.១ ខាងក្រោម អាចត្រូវបានកើតឡើង ឬត្រូវជាប់ពាក់ព័ន្ធ។

១២.៥.សមាជិកជាមជ្ឈត្តករត្រូវមានសិទ្ធិៈ

(ក) មានឈ្មោះជាមជ្ឈត្តករដែលបានចុះបញ្ជីនៅ ម.ជ.ម.។

(ខ) ចូលរួមកិច្ចប្រជុំមហាសន្និបាត និងបោះឆ្នោតលើបញ្ហានានា ដែលត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំនោះ។

(គ) ជាសមាជិកនៃគណៈកម្មាធិការណាមួយរបស់ ម.ជ.ម.។

(ឃ) បម្រើការក្នុងក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងផ្នែកណាមួយនៃ ម.ជ.ម.។

(ង) ធ្វើសកម្មភាពនានាដូចមានចែងក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១២៤។

១២.៦.នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីជាសមាជិកជាមជ្ឈត្តករៈ

(ក) បេក្ខជនត្រូវដាក់ពាក្យសុំពេញលេញ ព្រមជាមួយព័ត៌មានលំអិតសម្រាប់ការទាក់ទងជូន ម.ជ.ម. ដោយប្រើប្រាស់ទម្រង់ពាក្យសុំ "ក" ដែលមាននៅលើគេហទំព័រ និងនៅទីស្នាក់ការរបស់ ម.ជ.ម. ព្រមជាមួយឯកសារផ្សេងៗ ដែលបង្ហាញថាបេក្ខជនបានបំពេញលក្ខណសម្បត្តិដូចមានកំណត់ក្នុងប្រការ ១២.១ ឬប្រការ ១២.២ ខាងលើ និងភស្តុតាងបង្ហាញពីការបង់ប្រាក់កម្រៃ សម្រាប់ការដាក់ពាក្យសុំ ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំពេញលេញរួចមក គណៈកម្មាធិការសមាជិកភាព ត្រូវពិនិត្យមើលពាក្យសុំនោះ និងបញ្ជូនយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិដើម្បីសម្រេចចុងក្រោយ។ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបេក្ខជន អំពីការសម្រេចរបស់ខ្លួនចំពោះពាក្យសុំចុះបញ្ជីនោះ។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិ អាចពន្យារពេលសម្រេចរហូតដល់ ១៨០ (មួយរយប៉ែតសិប) ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

(គ) ប្រសិនបើបេក្ខជនមិនបានបំពេញលក្ខណសម្បត្តិតម្រូវទាំងឡាយ សម្រាប់ការចុះបញ្ជីទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវផ្តល់ដំណឹងដោយភ្ជាប់មូលហេតុទៅបេក្ខជនអំពីបញ្ហានេះ និងទុករយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន សម្រាប់ឱ្យបេក្ខជនផ្តល់ឯកសារបន្ថែម បង្ហាញថាបេក្ខជនពិតជាមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចដែលតម្រូវសម្រាប់ការចុះបញ្ជីនោះមែន។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះហើយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងទៅបេក្ខជន អំពីសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។

(ឃ) ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិសម្រេចថាបេក្ខជនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីគ្រប់គ្រាន់ហើយ អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីការបង់ភាគទានទាំងស្រុងនៃភាគទានប្រចាំឆ្នាំ ដែលត្រូវអនុវត្តចំពោះសមាជិកជាមជ្ឈត្តករស្របតាមប្រការ ១៧ ខាងក្រោម។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋាន ចុះបញ្ជីបេក្ខជនជាសមាជិកជាមជ្ឈត្តករនៅ ម.ជ.ម. ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទីមួយនៃខែបន្ទាប់ ក្រោយពីបានទទួលការបង់ភាគទានរហូតដល់ និងរួមបញ្ចូលថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។ អគ្គលេខាធិការ ត្រូវជូនដំណឹងទៅបេក្ខជនអំពីការចុះបញ្ជីនេះ។

១២.៧.នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីបន្តសារជាថ្មីប្រចាំឆ្នាំរបស់សមាជិកជាមជ្ឈត្តករ៖

(ក) ក្រោយពីបានទទួលការបង់ភាគទានប្រចាំឆ្នាំហើយ ម.ជ.ម. ត្រូវចុះបញ្ជីសមាជិកជាមជ្ឈត្តករបន្តសារជាថ្មីសម្រាប់ឆ្នាំក្រោយ លើកលែងតែ៖

ក.១-សមាជិកជាមជ្ឈត្តករបានជូនដំណឹងទៅ ម.ជ.ម. ថា ខ្លួនមិនមានបំណងចុះបញ្ជីបន្តសារជាថ្មីជាសមាជិកជាមជ្ឈត្តករ

ក.២-សមាជិកជាមជ្ឈត្តករមិនបានប្រលងជាប់ការប្រលងនៃវគ្គ ឬកម្មវិធីបណ្ដុះបណ្ដាលនានា ដែល ម.ជ.ម. បានតម្រូវក្នុងឆ្នាំបច្ចុប្បន្ន

ក.៣-មានករណីមួយ ឬច្រើនកំណត់ក្នុងប្រការ ១៩.១ ខាងក្រោម អាចត្រូវបានកើតឡើង ឬមានជាប់ពាក់ព័ន្ធនឹងសមាជិកជាមជ្ឈត្តករ ឬ

ក.៤-សមាជិកជាមជ្ឈត្តករខកខានមិនបានបញ្ជូនសេចក្ដីប្រកាសផ្ទាល់ខ្លួនក្នុងទម្រង់ដែលកំណត់ដោយ ម.ជ.ម. និងឯកសារផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីបញ្ជាក់ថាខ្លួននៅតែបំពេញបានលក្ខណសម្បត្តិ និងលក្ខខណ្ឌតម្រូវទាំងឡាយដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះ។

(ខ) ប្រសិនបើព័ត៌មានដែល ម.ជ.ម. បានកត់ត្រាទុកមានភាពមិនច្បាស់ ឬមិនគ្រប់គ្រាន់ ម.ជ.ម. អាចតម្រូវឱ្យសមាជិកជាមជ្ឈត្តករនោះផ្ដល់ព័ត៌មានបន្ថែម។ សមាជិកជាមជ្ឈត្តករ ត្រូវឆ្លើយតបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃដែលត្រូវបានស្នើសុំឱ្យផ្ដល់ព័ត៌មានបន្ថែម។

(គ) ប្រសិនបើសមាជិកជាមជ្ឈត្តករមិនបានបំពេញតាមលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជី បន្តសារជាថ្មីដូចមានរៀបរាប់ខាងលើទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវសម្រេចមិនចុះបញ្ជីបន្តសារជាថ្មីឱ្យសមាជិកជាមជ្ឈត្តកររូបនោះ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងដោយភ្ជាប់មូលហេតុទៅ

សមាជិកជាមជ្ឈត្តករូបនោះ។ សមាជិកជាមជ្ឈត្តករមានរយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ក្នុងការបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងបញ្ជូនឯកសារនានា ដើម្បីបង្ហាញពីមូលដ្ឋានថាការចុះបញ្ជីគួរតែត្រូវបានបន្តសារជាថ្មីសម្រាប់ឆ្នាំបន្ទាប់។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងទៅសមាជិកជាមជ្ឈត្តករអំពីការសម្រេចចុងក្រោយរបស់ខ្លួន។

(ឃ) ប្រសិនបើ ស្របតាមនីតិវិធីនៃប្រការនេះ សមាជិកជាមជ្ឈត្តករបានបំពេញលក្ខណសម្បត្តិទាំងអស់ដែលតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មី អគ្គលេខាធិការត្រូវផ្ញើវិក្កយបត្រសម្រាប់បង់ភាគទានប្រចាំឆ្នាំសម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះទៅសមាជិកជាមជ្ឈត្តករ។ បន្ទាប់ពីបានទទួលការបង់ទាំងស្រុងនៃភាគទានប្រចាំឆ្នាំ សម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះហើយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីសមាជិកជាមជ្ឈត្តករូបនោះបន្តសារជាថ្មី ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំដែលមានការចុះបញ្ជីបន្តសារជាថ្មីនោះ។

## ប្រការ ១៣. លក្ខណសម្បត្តិ និងការចុះបញ្ជីនីតិបុគ្គលជាសមាជិកជានីតិបុគ្គល

១៣.១.ដើម្បីចុះបញ្ជីនីតិបុគ្គលជាសមាជិកជានីតិបុគ្គលនៅ ម.ជ.ម. នីតិបុគ្គលត្រូវមានលក្ខណសម្បត្តិទាំងអស់ ដូចខាងក្រោម៖

(ក) នីតិបុគ្គលត្រូវតែស្ថិតក្នុងប្រភេទណាមួយនៃអង្គភាពខាងក្រោម៖

ក.១-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក.២-សភាពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឬ

ក.៣-រាល់សមាគម ដែលប្រមូលផ្តុំសមាជិកជាពាណិជ្ជករ ឧស្សាហករ អាជីវករ ឬសេវាករ

(ខ) ត្រូវបានបង្កើតឡើងដោយមានបុគ្គលភាពគតិយុត្តស្ថិតនៅក្រោម និងស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀត ព្រមទាំងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬនៅស្ថាប័នមានសមត្ថកិច្ចណាមួយ

(គ) មានប្រព័ន្ធអភិបាលកិច្ចច្បាស់លាស់ ក្រុមប្រឹក្សាភិបាល និងសមាជិកស្របតាមវិធានគ្រប់គ្រងរបស់ខ្លួន

(ឃ) មានសមាជិកយ៉ាងតិច ២០ (ម្ភៃ)

(ង) មានសកម្មភាពយ៉ាងសកម្មក្នុងកិច្ចការពាណិជ្ជកម្មដូចមានកំណត់ក្នុងមាត្រា២ (ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និង

(ច) នីតិបុគ្គលត្រូវមានឆន្ទៈក្នុងការចូលរួមចំណែកយ៉ាងសកម្មនៅក្នុងកម្មវត្ថុ និងសកម្មភាពរបស់ ម.ជ.ម.។

១៣.២.នៅពេលពិនិត្យពាក្យសុំចុះបញ្ជីជាសមាជិកជានីតិបុគ្គល ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាសមាគមពាណិជ្ជករ ឬសភាពាណិជ្ជកម្ម ដែលមានកំណត់ក្នុងប្រការ ១៣.១(ក) ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

(ក) តំណាងរាល់វិស័យសំខាន់ៗទាំងឡាយនៃសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានជាអាទិ៍ វិស័យហិរញ្ញវត្ថុ ផលិតកម្ម សំណង់ ឬកសិកម្ម

(ខ) តំណាងពាណិជ្ជកម្មខ្នាតធំ មធ្យម តូច ឬមីក្រូ

(គ) តំណាងទូទាំងប្រទេស និង

(ឃ) តំណាងពាណិជ្ជករខ្មែរ ឬបរទេសដែលកំពុងវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១៣.៣.តាមរយៈអ្នកតំណាងរបស់ខ្លួន សមាជិកជានីតិបុគ្គលត្រូវមានសិទ្ធិ៖

(ក) ចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាត និងបោះឆ្នោតលើបញ្ហានានាដែលត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំនោះ។

(ខ) ក្លាយជាសមាជិកនៃគណៈកម្មាធិការណាមួយរបស់ ម.ជ.ម.។

(គ) អាចឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងផ្នែកណាមួយនៃ ម.ជ.ម.។

(ឃ) ធ្វើសកម្មភាពនានាដូចមានចែងក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១២៤។

១៣.៤.សមាជិកជានីតិបុគ្គលនីមួយៗត្រូវតែងតាំងរូបវន្តបុគ្គលមួយរូបឱ្យធ្វើជាអ្នកតំណាងសម្រាប់ធ្វើសកម្មភាពនានាក្នុងនាមជាសមាជិកជានីតិបុគ្គលសម្រាប់គ្រប់កិច្ចការទាំងអស់របស់ ម.ជ.ម. រួមបញ្ចូលទាំងការតំណាងសមាជិកជានីតិបុគ្គលនៅក្នុងក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងគណៈកម្មាធិការនានា ប្រសិនបើសមាជិកជានីតិបុគ្គលនោះត្រូវបានជ្រើសតាំង ឬតែងតាំងតាមនីតិវិធីកំណត់។ ក្នុងចំណោមកិច្ចការផ្សេងៗ អ្នកតំណាងត្រូវចូលរួមបញ្ចេញយោបល់ និងបោះឆ្នោតក្នុងកិច្ចប្រជុំរបស់មហាសន្និបាត។ ដើម្បីជៀសវាងការភ័ន្តច្រឡំ អ្នកតំណាងមិនត្រូវបានចាត់ទុកជាសមាជិក ម.ជ.ម. ឡើយ។

១៣.៥.នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីជាសមាជិកជានីតិបុគ្គល៖

(ក) បេក្ខជនត្រូវដាក់ពាក្យសុំពេញលេញ ព្រមជាមួយព័ត៌មានលំអិតសម្រាប់ការទាក់ទងទៅ ម.ជ.ម. ដោយប្រើប្រាស់ទម្រង់ពាក្យសុំ "ខ" ដែលមាននៅលើគេហទំព័រ និងនៅទីស្នាក់ការរបស់ ម.ជ.ម. ព្រមជាមួយឯកសារ

ផ្សេងៗដែលបង្ហាញថាបេក្ខជនបានបំពេញលក្ខណសម្បត្តិដូចមានកំណត់ក្នុងប្រការ ១៣.១ ខាងលើ និងភស្តុតាងបង្ហាញពីការបង់ប្រាក់កម្រៃសម្រាប់ការដាក់ពាក្យសុំ ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំពេញលេញរួចមក គណៈកម្មាធិការសមាជិកភាពត្រូវពិនិត្យមើលពាក្យសុំនោះ និងបញ្ជូនយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិដើម្បីសម្រេចចុងក្រោយ។ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបេក្ខជន អំពីការសម្រេចរបស់ខ្លួនចំពោះពាក្យសុំចុះបញ្ជីនោះ។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិអាចពន្យារពេលសម្រេចរហូតដល់ ១៨០ (មួយរយប៉ែតសិប) ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

(គ) ប្រសិនបើ បេក្ខជនមិនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវផ្តល់ដំណឹងដោយភ្ជាប់មូលហេតុទៅបេក្ខជនអំពីបញ្ហានេះ និងទុករយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន សម្រាប់ឱ្យបេក្ខជនផ្តល់ឯកសារបន្ថែមបង្ហាញថាបេក្ខជនពិតជាមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចដែលតម្រូវសម្រាប់ការចុះបញ្ជីនោះមែន។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះហើយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងទៅបេក្ខជនអំពីសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។

(ឃ) ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិសម្រេចថា បេក្ខជនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជី អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីការបង់ភាគទានទាំងស្រុងនៃភាគទានប្រចាំឆ្នាំដែលត្រូវអនុវត្តចំពោះសមាជិកជានីតិបុគ្គលស្របតាមប្រការ ១៧ ខាងក្រោម។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីបេក្ខជនជាសមាជិកជានីតិបុគ្គល នៅ ម.ជ.ម. ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទីមួយនៃខែបន្ទាប់ ក្រោយពីបានទទួលការបង់ភាគទានរហូតដល់ និងរួមបញ្ចូលថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។ អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីបញ្ហានេះ។

១៣.៦.នីតិវិធីខាងក្រោម ត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីបន្តសារជាថ្មីប្រចាំឆ្នាំរបស់សមាជិកជានីតិបុគ្គល៖

(ក) ក្រោយពីបានទទួលការបង់ភាគទានប្រចាំឆ្នាំហើយ ម.ជ.ម. ត្រូវចុះបញ្ជីសមាជិកជានីតិបុគ្គលបន្តសារជាថ្មីសម្រាប់ឆ្នាំក្រោយ លើកលែងតែ៖

ក.១-សមាជិកជានីតិបុគ្គលបានជូនដំណឹងទៅ ម.ជ.ម. ថាខ្លួនមិនមានបំណងចុះបញ្ជីបន្តសារជាថ្មីជាសមាជិកជានីតិបុគ្គល

ក.២-មានករណីមួយ ឬច្រើនដែលកំណត់ក្នុងប្រការ ១៩.២ ខាងក្រោម អាចត្រូវបានកើតឡើង ឬមានជាប់ពាក់ព័ន្ធនឹងសមាជិកជានីតិបុគ្គល ឬ

ក.៣-សមាជិកជានីតិបុគ្គល ឬអ្នកតំណាងខកខានមិនបានបញ្ជូនសេចក្តីប្រកាសផ្ទាល់ខ្លួនក្នុងទម្រង់ដែលកំណត់ដោយ ម.ជ.ម. និងឯកសារផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីបញ្ជាក់ថាខ្លួននៅតែបំពេញលក្ខណសម្បត្តិ និងលក្ខខណ្ឌតម្រូវនានានៃបទបញ្ជាផ្ទៃក្នុងនេះ។

(ខ) ប្រសិនបើព័ត៌មានដែល ម.ជ.ម. មានកត់ត្រាទុកមានភាពមិនច្បាស់ ឬមិនគ្រប់គ្រាន់ ម.ជ.ម. អាចតម្រូវឱ្យសមាជិកជានីតិបុគ្គលផ្តល់ព័ត៌មានបន្ថែម។ សមាជិកជានីតិបុគ្គលត្រូវឆ្លើយតបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានបន្ថែម។

(គ) ប្រសិនបើសមាជិកជានីតិបុគ្គលមិនបានបំពេញតាមលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មីដូចមានរៀបរាប់ខាងលើទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវសម្រេចមិនចុះបញ្ជីបន្តសារជាថ្មីឱ្យសមាជិកជានីតិបុគ្គលនោះ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងដោយភ្ជាប់មូលហេតុទៅសមាជិកជានីតិបុគ្គលនោះ។ សមាជិកជានីតិបុគ្គលមានរយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ក្នុងការបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងបញ្ជូនឯកសារនានាបង្ហាញពីមូលដ្ឋានថាការចុះបញ្ជីគួរតែត្រូវបានបន្តសារជាថ្មីសម្រាប់ឆ្នាំបន្ទាប់។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងទៅសមាជិកជានីតិបុគ្គលអំពីការសម្រេចចុងក្រោយរបស់ខ្លួន។

(ឃ) ប្រសិនបើស្របតាមនីតិវិធីនៃប្រការនេះ សមាជិកជានីតិបុគ្គលបានបំពេញលក្ខណសម្បត្តិទាំងអស់ដែលតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មី អគ្គលេខាធិការត្រូវផ្ញើវិក្កយបត្របង់ភាគទានប្រចាំឆ្នាំសម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះទៅសមាជិកជានីតិបុគ្គល។ បន្ទាប់ពីបានទទួលការបង់ទាំងស្រុងនៃភាគទានប្រចាំឆ្នាំ សម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះហើយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីសមាជិកជានីតិបុគ្គលរូបនោះបន្តសារជាថ្មីដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំដែលមានការចុះបញ្ជីបន្តសារជាថ្មីនោះ។

## ប្រការ ១៤. លក្ខណសម្បត្តិនិងការចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកគាំទ្រជារូបវន្តបុគ្គល

១៤.១.ដើម្បីចុះបញ្ជីរូបវន្តបុគ្គលជាសមាជិកគាំទ្រជារូបវន្តបុគ្គលនៅ ម.ជ.ម. រូបវន្តបុគ្គលត្រូវមានលក្ខណសម្បត្តិទាំងអស់ដូចខាងក្រោម៖

(ក) មានអាយុយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ

(ខ) បានចុះបញ្ជីជានិស្សិតនៃមហាវិទ្យាល័យណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ឬមានបរិញ្ញាបត្រជំនាញណាមួយដែលចេញដោយមហាវិទ្យាល័យណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង

(គ) គ្មានករណីណាមួយក្នុងប្រការ ១៩.១ ខាងក្រោម ត្រូវយកមកអនុវត្តចំពោះរូបវន្តបុគ្គលនោះ។

១៤.២.សមាជិកគាំទ្រជារូបវន្តបុគ្គលមានសិទ្ធិ៖

(ក) ទទួលបានព័ត៌មានដែលផ្សព្វផ្សាយដោយ ម.ជ.ម. ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ចូលរួមក្នុងពិធីនានាដែលរៀបចំដោយ ម.ជ.ម. ក្នុងលក្ខខណ្ឌជាក់លាក់ណាមួយដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(គ) ចូលរួមក្នុងការបណ្តុះបណ្តាលផ្សេងៗដែលរៀបចំដោយ ម.ជ.ម. ក្នុងលក្ខខណ្ឌជាក់លាក់ណាមួយដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ឃ) មានឈ្មោះក្នុងបញ្ជីដែលបោះពុម្ពផ្សាយស្របតាមប្រការ ១៨។

១៤.៣.សមាជិកគាំទ្រជារូបវន្តបុគ្គលមិនត្រូវមានសិទ្ធិ៖

(ក) បោះឆ្នោតនៅក្នុងកិច្ចប្រជុំមហាសន្និបាតរបស់ ម.ជ.ម.។

(ខ) ជាសមាជិកនៃគណៈកម្មាធិការណាមួយរបស់ ម.ជ.ម.។

(គ) ឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម.។

១៤.៤.នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះការដាក់ពាក្យសុំចុះបញ្ជីជាសមាជិកគាំទ្រជារូបវន្តបុគ្គល៖

(ក) បេក្ខជនត្រូវដាក់ពាក្យសុំពេញលេញរបស់ខ្លួនព្រមជាមួយព័ត៌មានលំអិតសម្រាប់ការទាក់ទងទៅ ម.ជ.ម. ដោយប្រើប្រាស់ទម្រង់ពាក្យសុំ "គ" ដែលមាននៅលើគេហទំព័រនិងនៅទីស្នាក់ការរបស់ ម.ជ.ម. ភ្ជាប់ជាមួយឯកសារផ្សេងៗដែលបង្ហាញថាបេក្ខជនបានបំពេញលក្ខណសម្បត្តិដូចមានកំណត់ក្នុងប្រការ ១៤.១ ខាងលើ និងភស្តុតាងបង្ហាញពីការបង់ប្រាក់កម្រៃសម្រាប់ការដាក់ពាក្យសុំដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំពេញលេញរួចមក គណៈកម្មាធិការសមាជិកភាពត្រូវពិនិត្យមើលពាក្យសុំនោះ និងបញ្ជូនយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិដើម្បីសម្រេចចុងក្រោយ។ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបេក្ខជនអំពីការសម្រេចរបស់ខ្លួនចំពោះពាក្យសុំចុះបញ្ជីនេះ។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិអាចពន្យារពេលសម្រេចរហូតដល់ ១៨០ (មួយរយប៉ែតសិប) ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

(គ) ប្រសិនបើបេក្ខជនមិនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីនោះទេ ពាក្យសុំនោះនឹងត្រូវបានបដិសេធ ប៉ុន្តែបេក្ខជនមានសិទ្ធិដាក់ពាក្យសុំចុះបញ្ជីសារជាថ្មីបាន។

(ឃ) ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិសម្រេចថា បេក្ខជនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជី អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីការបង់ភាគទានទាំងស្រុងនៃភាគទានប្រចាំឆ្នាំ ដែលអនុវត្តចំពោះសមាជិកគាំទ្រជារូបវន្តបុគ្គលស្របតាមប្រការ ១៧ ខាងក្រោម។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីបេក្ខជនជាសមាជិកគាំទ្រជារូបវន្តបុគ្គលនៅ ម.ជ.ម. ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទីមួយនៃខែបន្ទាប់ក្រោយពីបានទទួលការបង់ភាគទានរហូតដល់ និងរួមបញ្ចូលថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល។ អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីបញ្ហានេះ។

១៤.៥. នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីបន្តសារជាថ្មីប្រចាំឆ្នាំរបស់សមាជិកគាំទ្រជារូបវន្តបុគ្គល៖

(ក) ក្រោយពីបានទទួលការបង់ភាគទានប្រចាំឆ្នាំហើយ ម.ជ.ម. ត្រូវចុះបញ្ជីសមាជិកគាំទ្រជារូបវន្តបុគ្គលបន្តសារជាថ្មីសម្រាប់ឆ្នាំក្រោយ លើកលែងតែ៖

ក.១-សមាជិកគាំទ្រជារូបវន្តបុគ្គលបានផ្តល់ដំណឹងទៅ ម.ជ.ម. ថាខ្លួនមិនមានបំណងចុះបញ្ជីបន្តសារជាថ្មីជាសមាជិកគាំទ្រជារូបវន្តបុគ្គល ឬ

ក.២-មានករណីមួយ ឬច្រើនដែលមានកំណត់ក្នុងប្រការ ១៩.១ ខាងក្រោមអាចត្រូវបានកើតឡើង ឬមានជាប់ពាក់ព័ន្ធនឹងសមាជិកគាំទ្រជារូបវន្តបុគ្គល។

(ខ) ប្រសិនបើព័ត៌មានដែល ម.ជ.ម. បានកត់ត្រាទុកមានភាពមិនច្បាស់ ឬមិនគ្រប់គ្រាន់ ម.ជ.ម. អាចតម្រូវឱ្យសមាជិកគាំទ្រជារូបវន្តបុគ្គលផ្តល់ព័ត៌មានបន្ថែម។ សមាជិកគាំទ្រជារូបវន្តបុគ្គលត្រូវឆ្លើយតបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានបន្ថែម ។

(គ) ប្រសិនបើសមាជិកគាំទ្រជារូបវន្តបុគ្គលមិនបានបំពេញតាមលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីសារជាថ្មីដូចមានរៀបរាប់ខាងលើទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវសម្រេចមិនចុះបញ្ជី បន្តសារជាថ្មីឱ្យសមាជិកគាំទ្រជារូបវន្តបុគ្គលរូបនោះ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹង ដោយភ្ជាប់មូលហេតុទៅសមាជិកគាំទ្រជារូបវន្តបុគ្គលនោះ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិគឺជាសេចក្តីសម្រេចស្ថាពរ និងមានអានុភាពចងកាតព្វកិច្ច។

(ឃ) ប្រសិនបើស្របតាមនីតិវិធីនៃប្រការនេះ សមាជិកគាំទ្រជារូបវន្តបុគ្គលបានបំពេញលក្ខណសម្បត្តិទាំងអស់ដែលតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មី ក្រុមប្រឹក្សាប្រតិបត្តិបន្ទាប់ពីបានទទួលការបង់ទាំងស្រុងនៃភាគទានប្រចាំឆ្នាំ សម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះហើយ ត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីសមាជិកគាំទ្រជារូបវន្តបុគ្គលរូបនោះបន្តសារជាថ្មី ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំ ដែលមានការចុះបញ្ជីបន្តសារជាថ្មីនោះ។

## ប្រការ ១៥. លក្ខណសម្បត្តិ និងការចុះបញ្ជីនីតិបុគ្គលជាសមាជិកគាំទ្រជានីតិបុគ្គល

១៥.១. លក្ខណសម្បត្តិសម្រាប់ការចុះបញ្ជីនីតិបុគ្គលជាសមាជិកគាំទ្រជានីតិបុគ្គលនៅ ម.ជ.ម. រួមមាន៖

(ក) ត្រូវបានបង្កើតឡើងដោយមានបុគ្គលភាពគតិយុត្តស្ថិតនៅក្រោម និងស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀត និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬស្ថាប័នមានសមត្ថកិច្ចណាមួយផ្សេងទៀត

(ខ) មានប្រព័ន្ធអភិបាលកិច្ចច្បាស់លាស់ ជាមួយនឹងក្រុមប្រឹក្សាភិបាល និងសមាជិក ស្របតាមវិធានគ្រប់គ្រងរបស់ខ្លួន និង

(គ) នីតិបុគ្គលត្រូវមានឆន្ទៈក្នុងការចូលរួមចំណែកយ៉ាងសកម្មនៅក្នុងកម្មវត្ថុ និងសកម្មភាពរបស់ ម.ជ.ម.។

១៥.២. សមាជិកគាំទ្រជានីតិបុគ្គលត្រូវមានសិទ្ធិ៖

(ក) ទទួលបានព័ត៌មានដែលផ្សព្វផ្សាយដោយ ម.ជ.ម. ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ចូលរួមក្នុងពិធីនានាដែលរៀបចំដោយ ម.ជ.ម. ក្នុងលក្ខខណ្ឌជាក់លាក់ណាមួយដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(គ) ចូលរួមក្នុងការបណ្តុះបណ្តាលផ្សេងៗដែលរៀបចំដោយ ម.ជ.ម. ក្នុងលក្ខខណ្ឌជាក់លាក់ណាមួយដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ឃ) មានឈ្មោះក្នុងបញ្ជីដែលបោះពុម្ពផ្សាយស្របតាមប្រការ ១៨។

១៥.៣. សមាជិកគាំទ្រជានីតិបុគ្គលមិនត្រូវមានសិទ្ធិ៖

(ក) បោះឆ្នោតនៅក្នុងកិច្ចប្រជុំមហាសន្និបាតរបស់ ម.ជ.ម.។

(ខ) ជាសមាជិកនៃគណៈកម្មាធិការណាមួយរបស់ ម.ជ.ម.។

(គ) បម្រើការក្នុងក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម.។

១៥.៤. នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះការដាក់ពាក្យសុំចុះបញ្ជីជាសមាជិកគាំទ្រជានីតិបុគ្គល៖

(ក) បេក្ខជនត្រូវដាក់ពាក្យសុំពេញលេញរបស់ខ្លួនព្រមជាមួយព័ត៌មានលំអិតសម្រាប់ការទាក់ទងទៅ ម.ជ.ម. ដោយប្រើប្រាស់ទម្រង់ពាក្យសុំ "ឃ" ដែលមាននៅលើគេហទំព័រ និងនៅទីស្នាក់ការរបស់ ម.ជ.ម. ភ្ជាប់ជាមួយឯកសារផ្សេងៗ ដែលបង្ហាញថាបេក្ខជនបានបំពេញលក្ខណសម្បត្តិដូចមានកំណត់ក្នុងប្រការ ១៥.១ខាងលើ និងភស្តុតាងបង្ហាញពីការបង់ប្រាក់កម្រៃសម្រាប់ការដាក់ពាក្យសុំដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

(ខ) ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំពេញលេញរួចមក គណៈកម្មាធិការសមាជិកភាពត្រូវពិនិត្យមើលពាក្យសុំនោះ និងបញ្ជូនយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិដើម្បីសម្រេចចុងក្រោយ។ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបេក្ខជនអំពីការសម្រេចរបស់ខ្លួនចំពោះពាក្យសុំចុះបញ្ជីនេះ។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិអាចពន្យារពេលសម្រេចរហូតដល់ ១៨០ (មួយរយប៉ែតសិប) ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

(គ) ប្រសិនបើបេក្ខជនមិនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីទេនោះ ពាក្យសុំនោះនឹងត្រូវបានបដិសេធ ប៉ុន្តែបេក្ខជនមានសិទ្ធិក្នុងការដាក់ពាក្យសុំចុះបញ្ជីសារជាថ្មីបាន។

(ឃ) ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិសម្រេចថា បេក្ខជនបានបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជី អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីការបង់ភាគទានទាំងស្រុងនៃភាគទានប្រចាំឆ្នាំដែលអនុវត្តចំពោះសមាជិកគាំទ្រជានីតិបុគ្គលស្របតាមប្រការ ១៧ ខាងក្រោម។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីបេក្ខជនជាសមាជិកគាំទ្រជានីតិបុគ្គលនៅ ម.ជ.ម. ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទីមួយនៃខែបន្ទាប់ក្រោយពីបានទទួលការបង់ភាគទាន រហូតដល់និងរួមបញ្ចូលថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល។ អគ្គលេខាធិការត្រូវជូនដំណឹងទៅបេក្ខជនអំពីបញ្ហានេះ។

១៥.៥. នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំចុះបញ្ជីបន្តសារជាថ្មីប្រចាំឆ្នាំរបស់សមាជិកគាំទ្រជានីតិបុគ្គលៈ

(ក) ក្រោយពីបានទទួលការបង់ភាគទានប្រចាំឆ្នាំហើយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវចុះបញ្ជីសមាជិក គាំទ្រជានីតិបុគ្គលបន្តសារជាថ្មីសម្រាប់ឆ្នាំក្រោយ លើកលែងតែៈ

ក.១-សមាជិកគាំទ្រជានីតិបុគ្គលបានផ្តល់ដំណឹងទៅ ម.ជ.ម. ថាខ្លួនមិនមានបំណងចុះបញ្ជីបន្តសារជាថ្មីជាសមាជិកគាំទ្រជានីតិបុគ្គល ឬ

ក.២-មានករណីមួយឬច្រើនដែលកំណត់ក្នុងប្រការ ១៩.២ ខាងក្រោមអាចត្រូវបានកើតឡើង ឬមានជាប់ពាក់ព័ន្ធនឹងសមាជិកគាំទ្រជានីតិបុគ្គល។

(ខ) ប្រសិនបើព័ត៌មានដែល ម.ជ.ម. បានកត់ត្រាទុកមានភាពមិនច្បាស់ ឬមិនគ្រប់គ្រាន់ ក្រុមប្រឹក្សាប្រតិបត្តិអាចតម្រូវឱ្យសមាជិកគាំទ្រជានីតិបុគ្គលផ្តល់ព័ត៌មានបន្ថែម។ សមាជិកគាំទ្រ ជានីតិបុគ្គលត្រូវឆ្លើយតបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានបន្ថែម។

(គ) ប្រសិនបើសមាជិកគាំទ្រជានីតិបុគ្គលមិនបានបំពេញតាមលក្ខណសម្បត្តិទាំងអស់ ដែលតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មីដូចមានរៀបរាប់ខាងលើទេនោះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវសម្រេចមិនចុះបញ្ជីបន្តសារជាថ្មីឱ្យសមាជិកគាំទ្រជានីតិបុគ្គលរូបនោះ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងដោយភ្ជាប់មូលហេតុទៅសមាជិកគាំទ្រជានីតិបុគ្គលនោះ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិគឺជាសេចក្តីសម្រេចចុងក្រោយ និងមានអានុភាពអនុវត្ត។

(ឃ) ប្រសិនបើស្របតាមនីតិវិធីនៃប្រការនេះ សមាជិកគាំទ្រជានីតិបុគ្គលបានបំពេញលក្ខណសម្បត្តិទាំងអស់ដែលតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មី ក្រុមប្រឹក្សាប្រតិបត្តិបន្ទាប់ពីបានទទួលការបង់ទាំងស្រុងនៃភាគទានប្រចាំឆ្នាំសម្រាប់ឆ្នាំដែលត្រូវចុះបញ្ជីបន្តសារជាថ្មីនោះហើយ ត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីសមាជិកគាំទ្រជានីតិបុគ្គលរូបនោះបន្តសារជាថ្មី ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែមករា នៃឆ្នាំដែលមានការចុះបញ្ជីបន្តសារជាថ្មីនោះ។

## ប្រការ ១៦. ការអនុគ្រោះពេលវេលាកំណត់

ដោយមូលហេតុពិសេសណាមួយ ក្រុមប្រឹក្សាប្រតិបត្តិអាចផ្តល់ការអនុគ្រោះចំពោះពេលវេលាណាមួយ ដែលកំណត់ក្នុងប្រការ ១២ ប្រការ ១៣ ប្រការ ១៤ និងប្រការ ១៥ ខាងលើ។

## ប្រការ ១៧. ភាគទាន

ភាគទានប្រចាំឆ្នាំរបស់សមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្តបុគ្គល និងសមាជិកគាំទ្រជានីតិបុគ្គល ត្រូវកំណត់ និងកែប្រែដោយមហាសន្និបាត។ ស្របតាមតម្រូវការ និងស្ថេរភាពផ្នែកហិរញ្ញវត្ថុរបស់ ម.ជ.ម. មហាសន្និបាតអាចផ្ទេរសិទ្ធិក្នុងការកំណត់ ឬកែប្រែភាគទានប្រចាំឆ្នាំទៅក្រុមប្រឹក្សាប្រតិបត្តិ។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅសមាជិកទាំងអស់អំពីការផ្លាស់ប្តូភាគទាន មុនការចាប់ផ្តើមនៃឆ្នាំនីមួយៗដែលការផ្លាស់ប្តូរនឹងត្រូវអនុវត្ត។

ចំពោះសមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្តបុគ្គល និងសមាជិកគាំទ្រជានីតិបុគ្គល ដែលបានទទួលសមាជិកភាពនៅ ម.ជ.ម. មុន ឬនៅថ្ងៃទី០១ ខែកក្កដា ត្រូវបង់ភាគទានប្រចាំឆ្នាំទាំងស្រុង។ ចំពោះសមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្តបុគ្គល និងសមាជិកគាំទ្រជានីតិបុគ្គល ដែលបានទទួលសមាជិកភាពក្នុង ម.ជ.ម. នៅថ្ងៃទី០២ ខែកក្កដា ឬក្រោយ ត្រូវបង់ភាគទានប្រចាំឆ្នាំពាក់កណ្តាលនៃតម្លៃភាគទានប្រចាំឆ្នាំទាំងស្រុង។

ភាគទានប្រចាំឆ្នាំរបស់ ម.ជ.ម. សម្រាប់សមាជិកជានីតិបុគ្គល ត្រូវមានតម្លៃពីរដងនៃភាគទានប្រចាំឆ្នាំរបស់សមាជិកជាមជ្ឈត្តករ និងភាគទានប្រចាំឆ្នាំរបស់ ម.ជ.ម. សម្រាប់សមាជិកគាំទ្រជានីតិបុគ្គល ត្រូវមានតម្លៃពីរដងនៃភាគទានប្រចាំឆ្នាំរបស់សមាជិកគាំទ្រជារូបវន្តបុគ្គល។

## ប្រការ ១៨. ទិន្នន័យ និងបញ្ជីផ្សេងៗ

១៨.១.រាល់សមាជិកជាមជ្ឈត្តករ សមាជិកជានីតិបុគ្គល សមាជិកគាំទ្រជារូបវន្តបុគ្គល សមាជិកគាំទ្រជានីតិបុគ្គល គ្រប់ពេលវេលាទាំងអស់ ត្រូវជូនដំណឹងដល់អគ្គលេខាធិការដ្ឋានអំពីការផ្លាស់ប្តូរព័ត៌មានលំអិតសម្រាប់ការទាក់ទងរបស់ខ្លួន។

១៨.២.អគ្គលេខាធិការដ្ឋានត្រូវរៀបចំ និងរក្សាបញ្ជីរបស់សមាជិករបស់ ម.ជ.ម. ចំនួន ៤ (បួន) បញ្ជី ដោយឡែកៗពីគ្នា៖

(ក) បញ្ជី "ក" សម្រាប់សមាជិកជាមជ្ឈត្តករ

(ខ) បញ្ជី "ខ" សម្រាប់សមាជិកជានីតិបុគ្គល

(គ) បញ្ជី "គ" សម្រាប់សមាជិកគាំទ្រជារូបវន្តបុគ្គល និង

(ឃ) បញ្ជី "ឃ" សម្រាប់សមាជិកគាំទ្រជានីតិបុគ្គល។

## ប្រការ ១៩. ការបញ្ចប់សមាជិកភាព

១៩.១.ក្រុមប្រឹក្សាប្រតិបត្តិត្រូវបញ្ចប់សមាជិកភាពរបស់សមាជិកជាមជ្ឈត្តករ ឬសមាជិកគាំទ្រជារូបវន្តបុគ្គល ដែលបានចុះបញ្ជីនៅ ម.ជ.ម. ប្រសិនបើបុគ្គលរូបនោះ៖

(ក) ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ ឬសតិស្មារតី មិនអាចបំពេញតួនាទីរបស់ខ្លួនបាន

(ខ) ត្រូវបានប្រកាសក្ស័យធន ឬត្រូវបានដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី

(គ) បានដាក់ពាក្យលាឈប់ជាលាយលក្ខណ៍អក្សរទៅ ម.ជ.ម.

(ឃ) ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(ង) បានបំពានលើក្រមសីលធម៌របស់មជ្ឈត្តករ ឬវិធានណាមួយរបស់ ម.ជ.ម.

(ច) បានបំពានលើកាតព្វកិច្ចរក្សាការសម្ងាត់ ដែលខ្លួនមានចំពោះ ម.ជ.ម.

(ឆ) បានធ្វើសកម្មភាព ឬមានជាប់ពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ នយោបាយ ច្បាប់ ឬសង្គម ដែលអាចនាំឱ្យអាប់ឱន ឬប៉ះពាល់ដល់ភាពសុចរិតរបស់ ម.ជ.ម.

(ជ) បានទទួលមរណភាព ឬ

(ឈ) ខកខានមិនបានបង់ភាគទានប្រចាំឆ្នាំដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលវិក្កយត្រ ត្រូវបង់ភាគទាន។

១៩.២.ក្រុមប្រឹក្សាប្រតិបត្តិត្រូវបញ្ចប់សមាជិកភាពរបស់សមាជិកជានីតិបុគ្គល ឬសមាជិកគាំទ្រជានីតិបុគ្គល ប្រសិនបើនីតិបុគ្គលនោះ៖

(ក) ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី

(ខ) បានដាក់ពាក្យលាឈប់ជាលាយលក្ខណ៍អក្សរទៅ ម.ជ.ម.

(គ) ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(ឃ) បានបំពានលើវិធានណាមួយរបស់ ម.ជ.ម.

(ង) បានបំពានលើកាតព្វកិច្ចរក្សាការសម្ងាត់ ដែលខ្លួនមានចំពោះ ម.ជ.ម.

(ច) បានធ្វើសកម្មភាព ឬមានជាប់ពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ នយោបាយ ច្បាប់ ឬសង្គម ដែលអាចនាំឱ្យអាប់ឱន ឬប៉ះពាល់ដល់ភាពសុចរិតរបស់ ម.ជ.ម.

(ឆ) ត្រូវបានប្រកាសក្ស័យធន ឬ

(ជ) ខកខានមិនបានបង់ភាគទានប្រចាំឆ្នាំ ដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលវិក្កយបត្រ ត្រូវបង់ភាគទាន។

## ប្រការ ២០. នីតិវិធីនៃការបញ្ចប់សមាជិកភាព

២០.១.ក្នុងករណីដូចមានចែងក្នុងប្រការ ១៩.១ (ខ) (គ) (ឃ) និង (ជ) និងប្រការ ១៩.២ (ក) (ខ) (គ) និង (ឆ) សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើឡើងជាស្វ័យប្រវត្តិ និងមានប្រសិទ្ធភាពអនុវត្តភ្លាម។ ចំពោះករណីផ្សេងទៀត ក្រុមប្រឹក្សាប្រតិបត្តិត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចដែលខ្លួនត្រៀមនឹងបញ្ចប់សមាជិកភាពទៅសមាជិករបស់ ម.ជ.ម. សាមី និងផ្តល់រយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ចំពោះសមាជិកនោះ សម្រាប់ផ្តល់ការពន្យល់ជាលាយលក្ខណ៍អក្សរ។ សមាជិកភាពនឹងត្រូវបានបញ្ចប់ ប្រសិនបើសមាជិករបស់ ម.ជ.ម. នោះខកខានមិនបានផ្តល់ការពន្យល់ច្បាស់លាស់គ្រប់គ្រាន់ក្នុងអំឡុងពេលខាងលើ។

២០.២.នៅក្នុងករណីដទៃទៀតដែលមានចែងក្នុងប្រការ ១៩.១ និងប្រការ ១៩.២ ខាងលើ ក្រុមប្រឹក្សាប្រតិបត្តិត្រូវបញ្ជាក់គោលបំណងក្នុងការបញ្ចប់ និងបញ្ជូនសេចក្តីពន្យល់របស់រូបវន្តបុគ្គល ឬនីតិបុគ្គលទៅគណៈកម្មាធិការវិន័យ ដូចមានកំណត់ក្នុងប្រការ ៣៤.៣ខាងក្រោម ហើយគណៈកម្មាធិការវិន័យត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិវិញក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន។ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើការសម្រេចចុងក្រោយបន្ទាប់ពីបានពិចារណាយោបល់របស់គណៈកម្មាធិការវិន័យ។

## ប្រការ ២១. អានុភាពនៃការមិនបន្តសារជាថ្មី និងការបញ្ចប់សមាជិកភាព

នៅពេលដែលសមាជិកភាពត្រូវបានបញ្ចប់ ឬមិនត្រូវបានបន្តសារជាថ្មី អតីតសមាជិកមិនត្រូវមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់មហាសន្និបាត ឬមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។ ឈ្មោះនិងទិន្នន័យផ្សេងៗរបស់អតីតសមាជិករូបនោះនឹងត្រូវដកចេញពីបញ្ជីសមាជិក ម.ជ.ម. ។ ប្រសិនបើអតីតសមាជិក ឬអ្នកតំណាងរបស់អតីតសមាជិក ជាសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ឬគណៈកម្មាធិការណាមួយរបស់ ម.ជ.ម. សមាជិកភាពរបស់អតីតសមាជិករូបនោះក្នុងក្រុមប្រឹក្សាប្រតិបត្តិ ឬក្នុងគណៈកម្មាធិការ ក៏ត្រូវបញ្ចប់ជាស្វ័យប្រវត្តិផងដែរ។

ប្រសិនបើសមាជិកជាមជ្ឈត្តករត្រូវបាត់បង់សមាជិកភាពនៅ ម.ជ.ម. នៅពេលដែលសមាជិកជាមជ្ឈត្តកររូបនោះកំពុងធ្វើជាមជ្ឈត្តករនៃដំណើរការមជ្ឈត្តការនៅ ម.ជ.ម. អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីវិវាទ និងសមាជិកផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្មអំពីការបាត់បង់សមាជិកភាពរបស់មជ្ឈត្តកររូបនោះ និងតាមការសមស្រប អាចភ្ជាប់មូលហេតុអំពីការបាត់បង់សមាជិកភាពរបស់មជ្ឈត្តករនោះ។ ភាគីវិវាទត្រូវមានសេរីភាពជ្រើសរើស រក្សាទុក ឬដកមជ្ឈត្តកររូបនោះចេញពីដំណើរការមជ្ឈត្តការ ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ។

## ប្រការ ២២. ការដកហូតអ្នកតំណាង

២២.១.ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន សមាជិកជានីតិបុគ្គល ឬសមាជិកគាំទ្រជានីតិបុគ្គលត្រូវដកចេញអ្នកតំណាងរបស់ខ្លួន និងតែងតាំងអ្នកតំណាងផ្សេងទៀត ប្រសិនបើករណីណាមួយដូចខាងក្រោមត្រូវយកមកអនុវត្តចំពោះអ្នកតំណាងរបស់ខ្លួន៖

(ក) អ្នកតំណាងក្លាយជាអសមត្ថជនផ្នែករូបរាងកាយ ឬសតិស្មារតី មិនអាចបំពេញតួនាទីរបស់ខ្លួនបាន

(ខ) អ្នកតំណាងត្រូវបានប្រកាសក្ស័យធន ឬត្រូវបានដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី

(គ) អ្នកតំណាងត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(ឃ) អ្នកតំណាងបានបំពានលើវិធានណាមួយរបស់ ម.ជ.ម.

(ង) អ្នកតំណាងបានបំពានលើកាតព្វកិច្ចរក្សាការសម្ងាត់ ដែលខ្លួនមានចំពោះ ម.ជ.ម.

(ច) អ្នកតំណាងបានធ្វើសកម្មភាព ឬមានជាប់ពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ នយោបាយ ច្បាប់ ឬសង្គម ដែលអាចនាំឱ្យអាប់ឱន ឬប៉ះពាល់ដល់ភាពសុចរិតរបស់ ម.ជ.ម.

(ឆ) អ្នកតំណាងបានទទួលមរណភាព ឬ

(ជ) អ្នកតំណាងបានសុំលាឈប់ជាអ្នកតំណាង។

២២.២.ប្រសិនបើសមាជិកជានីតិបុគ្គល ឬសមាជិកគាំទ្រជានីតិបុគ្គល ខកខានក្នុងការគោរពតាមប្រការ២២.១ និងដោយមិនបានបង្ហាញមូលហេតុសមស្របទៅក្រុមប្រឹក្សាប្រតិបត្តិ សមាជិកភាពនៃសមាជិកជានីតិបុគ្គល ឬសមាជិកគាំទ្រជានីតិបុគ្គលដែលពាក់ព័ន្ធក៏ត្រូវចាត់ទុកថាបានបញ្ចប់ផងដែរ។

## ជំពូកទី ៤

# មហាសន្និបាត

### ប្រការ ២៣. សមត្ថកិច្ចរបស់មហាសន្និបាត

មហាសន្និបាតរបស់ ម.ជ.ម. គឺជាកិច្ចប្រជុំនៃសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់។ ដើម្បីជៀសវាងការភ័ន្តច្រឡំ សមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត គឺជាសមាជិកដែលបានបង់រាល់ភាគទានប្រចាំឆ្នាំគ្រប់ចំនួនមក ម.ជ.ម. ។

មហាសន្និបាតមានតួនាទីដូចខាងក្រោម៖

(ក) ពិភាក្សា និងសម្រេចលើរបាយការណ៍គ្រប់គ្រងប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុកន្លងមក

(ខ) ពិភាក្សា និងសម្រេចថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំហិរញ្ញវត្ថុចរន្ត និងថវិកាសម្រាប់ត្រីមាសទីមួយ សម្រាប់ឆ្នាំហិរញ្ញវត្ថុបន្ទាប់

(គ) ជ្រើសតាំង និងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ

(ឃ) អនុម័ត និងតាមការចាំបាច់ ធ្វើវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុង និងវិធានផ្សេងៗរបស់ ម.ជ.ម.

(ង) អនុម័ត និងតាមការចាំបាច់ ធ្វើវិសោធនកម្មលើវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. តារាងកម្រៃផ្សេងៗសម្រាប់ដំណើរការមជ្ឈត្តការ និងក្រមសីលធម៌មជ្ឈត្តករ

(ច) អនុម័ត និងតាមការចាំបាច់ ធ្វើវិសោធនកម្មលើនីតិវិធីចុះបញ្ជីរបស់រូបវន្តបុគ្គល និងនីតិបុគ្គល រួមបញ្ចូលទាំងលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជី និងការកំណត់ភាគទានដែលសមាជិក ម.ជ.ម. ត្រូវបង់ និង

(ឆ) តាមការចាំបាច់ អាចផ្ទេរសិទ្ធិរបស់ខ្លួនមួយផ្នែកជូនក្រុមប្រឹក្សាប្រតិបត្តិ។

## ប្រការ ២៤. កិច្ចប្រជុំរបស់មហាសន្និបាត

២៤.១.មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងមួយដងក្នុងមួយឆ្នាំ ក្នុងត្រីមាសទីមួយនៃឆ្នាំប្រតិទិននីមួយៗនៅកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងកាលៈទេសៈពិសេស និងស្របតាមភាពចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិអាចលើកកាលបរិច្ឆេទនៃមហាសន្និបាតប្រចាំឆ្នាំ ទៅកាលបរិច្ឆេទផ្សេងពីត្រីមាសទីមួយនៃឆ្នាំប្រតិទិន។ សេចក្តីជូនដំណឹងអំពីមហាសន្និបាតប្រចាំឆ្នាំ រួមបញ្ចូលទាំងព័ត៌មានអំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈ ត្រូវបញ្ជូនទៅសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់យ៉ាងតិច ៣០ (សាមសិប) ថ្ងៃប្រតិទិនមុនកាលបរិច្ឆេទប្រជុំ។

ក្នុងកាលៈទេសៈពិសេស និងស្របតាមភាពចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់ធ្វើមហាសន្និបាតប្រចាំឆ្នាំ ដោយមានការចូលរួមពីចម្ងាយតាមរយៈសន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀត ជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន។

ក្នុងករណីដែលមហាសន្និបាតប្រចាំឆ្នាំ ត្រូវបោះឆ្នោតជ្រើសតាំង និងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាតប្រចាំឆ្នាំនោះត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬតាមរយៈសិទ្ធិប្រទាន លើកលែងតែក្រុមប្រឹក្សាប្រតិបត្តិសម្រេចផ្សេងពីនេះ ដោយផ្អែកលើកាលៈទេសៈពិសេស និងស្របតាមភាពចាំបាច់។

២៤.២.មហាសន្និបាតវិសាមញ្ញអាចត្រូវបានស្នើឡើងដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ។ បន្ទាប់ពីមានការស្នើសុំប្រធានក្រុមប្រឹក្សាប្រតិបត្តិត្រូវជូនដំណឹងអំពីមហាសន្និបាតវិសាមញ្ញនោះរួមបញ្ចូលទាំងព័ត៌មានអំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈ ទៅសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់យ៉ាងតិច ១០ (ដប់) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទប្រជុំ។ ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិមិនបានបើកកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការស្នើសុំខាងលើទេ សមាជិកក្រុមប្រឹក្សាប្រតិបត្តិដែលបានស្នើសុំមហាសន្និបាតវិសាមញ្ញនោះអាចបើកកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ បន្ទាប់ពីបានជូនដំណឹងរយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន អំពីកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញនោះ រួមបញ្ចូលទាំងព័ត៌មានអំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈ ទៅសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត

ទាំងអស់។ សេចក្តីជូនដំណឹង និងកិច្ចការនានាដែលត្រូវលើកមកពិភាក្សា ត្រូវមានផ្សព្វផ្សាយនៅលើក្តារខៀនព័ត៌មានរបស់ ម.ជ.ម. លើគេហទំព័ររបស់ ម.ជ.ម. ឬត្រូវបញ្ជូនជាព័ត៌មានតាមមធ្យោបាយនានា ដែលក្រុមប្រឹក្សាប្រតិបត្តិចាត់ទុកថាសមស្របសម្រាប់កាលៈទេសៈនោះ។

២៤.៣.កិច្ចប្រជុំរបស់មហាសន្និបាតត្រូវប្រារព្ធធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬអនុប្រធានក្រុមប្រឹក្សាប្រតិបត្តិ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាប្រតិបត្តិអវត្តមាន។

២៤.៤.រាល់ឯកសារ ដែលពាក់ព័ន្ធនឹងកិច្ចការនានា ដែលត្រូវលើកមកពិភាក្សាក្នុងកិច្ចប្រជុំរបស់មហាសន្និបាត ត្រូវបញ្ជូនទៅគ្រប់សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់យ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទប្រជុំ។ កិច្ចប្រជុំរបស់មហាសន្និបាតអាចត្រូវបានចូលរួមដោយសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត និងអគ្គលេខាធិការតែប៉ុណ្ណោះ។ សមាជិក ម.ជ.ម មានសិទ្ធិបោះឆ្នោតនីមួយៗមានសិទ្ធិបោះឆ្នោតមួយសំឡេង។ អគ្គលេខាធិការមានសិទ្ធិបញ្ចេញយោបល់ ប៉ុន្តែមិនមានសិទ្ធិក្នុងការបោះឆ្នោតនោះទេ។ អគ្គលេខាធិការត្រូវចាកចេញពីកិច្ចប្រជុំតាមសំណើភាគច្រើនរបស់សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតដែលចូលរួមក្នុងកិច្ចប្រជុំដោយផ្ទាល់ខ្លួន និងដោយសិទ្ធិប្រទាន។

ក្រុមប្រឹក្សាប្រតិបត្តិអាចអញ្ជើញបុគ្គលមួយរូប ឬច្រើនរូប ឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្នុងផ្នែកណាមួយនៃកិច្ចប្រជុំ សម្រាប់គោលបំណងជាក់លាក់ណាមួយ។

២៤.៥.សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតប៉ុន្តែមិនអាចចូលរួមក្នុងកិច្ចប្រជុំណាមួយរបស់មហាសន្និបាត អាចផ្តល់សិទ្ធិប្រទានជាលាយលក្ខណ៍អក្សរទៅសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតផ្សេងទៀតតំណាងខ្លួន និងបោះឆ្នោតក្នុងនាមខ្លួនក្នុងកិច្ចប្រជុំនោះបាន។ សមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតមួយរូប អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ។ ការប្រគល់សិទ្ធិប្រទានត្រូវប្រកាសក្នុងកិច្ចប្រជុំ ហើយលិខិតប្រទានសិទ្ធិត្រូវភ្ជាប់ជាកំណត់ត្រានៃកិច្ចប្រជុំនោះ។

ដើម្បីជៀសវាងការភ័ន្តច្រឡំ សមាជិកជានីតិបុគ្គល មិនចាំបាច់មានការប្រគល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងរបស់ខ្លួនឡើយ។

២៤.៦.កូរ៉ុមនៃកិច្ចប្រជុំរបស់មហាសន្និបាតគឺវត្តមានយ៉ាងតិច ២/៣ (ពីរភាគបី) នៃសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដោយរាប់បញ្ចូលទាំងការចូលរួមដោយផ្ទាល់ ឬតាមរយៈសិទ្ធិប្រទាន។ ក្នុងករណីដែលកិច្ចប្រជុំមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុមិនគ្រប់កូរ៉ុម កិច្ចប្រជុំត្រូវលើកទៅប្រជុំនៅ ១៤ (ដប់បួន) ថ្ងៃប្រតិទិនក្រោយ តាមពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈដដែល។ កូរ៉ុមនៃកិច្ចប្រជុំដែលត្រូវបានលើកពេលនេះ គឺវត្តមាន ១/២ (មួយភាគពីរ) នៃសមាជិក ម.ជ.ម. ដែល

មានសិទ្ធិបោះឆ្នោតទាំងអស់ដោយរាប់បញ្ចូលទាំងការចូលរួមដោយផ្ទាល់ និងតាមរយៈសិទ្ធិប្រទាន។

ក្នុងករណីដែលកិច្ចប្រជុំលើកទី២ នៅតែមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុមិនគ្រប់កូរ៉ុម កិច្ចប្រជុំនោះនឹងត្រូវលើកទៅ ១៤ (ដប់បួន) ថ្ងៃប្រតិទិនក្រោយទៀតតាមពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈដដែល។ វត្តមានរបស់សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ទោះដោយផ្ទាល់ ឬដោយសិទ្ធិប្រទានក្នុងកិច្ចប្រជុំលើកក្រោយនេះ នឹងបង្កើតជាកូរ៉ុមសម្រាប់កិច្ចប្រជុំនោះ។

ក្នុងករណីដែលមហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើង ដោយមានការចូលរួមពីចម្ងាយតាមរយៈ សន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិត នៅទីកន្លែងមួយ ឬច្រើន ស្របតាមប្រការ ២៤.១ វត្តមានរបស់សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត តាមរយៈសន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតទាំងនោះ ព្រមទាំងសិទ្ធិប្រទាននឹងត្រូវរាប់សម្រាប់កំណត់កូរ៉ុម ដូចមានតម្រូវក្នុងកថាខណ្ឌខាងលើ។

២៤.៧. ដើម្បីមានសុពលភាពអនុវត្ត រាល់សេចក្តីសម្រេចរបស់មហាសន្និបាតត្រូវសម្រេចដោយសំឡេងគាំទ្រភាគច្រើន ហាសិបភាគរយបូកមួយ (៥០%បូក១) នៃសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដែលចូលរួមកិច្ចប្រជុំដោយផ្ទាល់ និងតាមរយៈសិទ្ធិប្រទាន។

២៤.៨. សមាជិក ម.ជ.ម. មានសិទ្ធិបោះឆ្នោតទាំងអស់ ដែលមានវត្តមានដោយផ្ទាល់ក្នុងកិច្ចប្រជុំមហាសន្និបាត អាច៖

(ក) ធ្វើសេចក្តីសម្រេចលើបញ្ហាដែលមិនត្រូវបានដាក់ក្នុងរបៀបវារៈ ដែលត្រូវលើកមកពិភាក្សាក្នុងកិច្ចប្រជុំ និង

(ខ) ធ្វើសេចក្តីសម្រេច បើទោះបីជាកិច្ចប្រជុំមិនត្រូវបានកោះអញ្ជើញត្រឹមត្រូវតាមនីតិវិធីជាធរមាន។

២៤.៩. ការបោះឆ្នោតត្រូវធ្វើឡើងជាការសម្ងាត់ លើកលែងតែមហាសន្និបាតសម្រេចជ្រើសរើសយកវិធីបោះឆ្នោតតាមរយៈការលើកដៃ។ ការសម្រេចដោយមហាសន្និបាតអំពីការជ្រើសរើសវិធីបោះឆ្នោតដោយលើកដៃនេះ ត្រូវធ្វើឡើងតាមរយៈការលើកដៃ។

ក្នុងករណីដែលមហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើង ដោយមានការចូលរួមពីចម្ងាយតាមរយៈ សន្និសីទវីដេអូ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀត ជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន ស្របតាមប្រការ ២៤.១ ការបោះឆ្នោតត្រូវធ្វើឡើងតាមរយៈការលើកដៃ ឬតាមរយៈមធ្យោបាយបោះឆ្នោតអេឡិចត្រូនិចដែលអាចធានាបាននូវសុច្ចរិតភាពនៃការបោះឆ្នោត។

២៤.១០.ប្រធានត្រូវតែងតាំងបុគ្គលយ៉ាងតិចមួយរូប ក្នុងចំណោមអ្នកដែលមានវត្តមានក្នុងកិច្ចប្រជុំមហាសន្និបាត ឬក្នុងចំណោមបុគ្គលិកនៃអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. ឱ្យកត់ត្រាកំណត់ហេតុប្រជុំ។ កំណត់ហេតុប្រជុំត្រូវមានបញ្ជាក់កាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ ឈ្មោះអ្នកចូលរួមដែលមានវត្តមានដោយផ្ទាល់ និងតាមរយៈសិទ្ធិប្រទាន និងសេចក្តីសម្រេចដែលបានត្រូវបានអនុម័ត ឬបដិសេធ។ កំណត់ហេតុប្រជុំត្រូវបញ្ជាក់ផងដែរអំពីចំនួនសំឡេងឆ្នោតនៃសេចក្តីសម្រេច។ កំណត់ហេតុប្រជុំ ត្រូវចុះហត្ថលេខាដោយប្រធាន និងអ្នកដែលទទួលកត់ត្រាកំណត់ហេតុប្រជុំនោះ។

## ជំពូកទី ៥

# ក្រុមប្រឹក្សាប្រតិបត្តិ

### ប្រការ ២៥. ក្រុមប្រឹក្សាប្រតិបត្តិ និងសមត្ថកិច្ច

២៥.១.ម.ជ.ម. ត្រូវបង្កើតក្រុមប្រឹក្សាប្រតិបត្តិ ដែលមានតួនាទីដូចតទៅ ៖

(ក) គ្រប់គ្រង និងសម្រេចការងារប្រចាំថ្ងៃរបស់ ម.ជ.ម.

(ខ) បង្កើត និងអនុម័តគោលនយោបាយរបស់ ម.ជ.ម.

(គ) រៀបចំតាក់តែង ពិនិត្យ និងកែប្រែវិធាន និងនីតិវិធីនានារបស់ ម.ជ.ម. ឱ្យកាន់តែមានភាពប្រសើរឡើង

(ឃ) រៀបចំ និងត្រួតពិនិត្យសកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈសម្រាប់មជ្ឈត្តកររបស់ ម.ជ.ម.

(ង) តែងតាំង និងត្រួតពិនិត្យសកម្មភាពការងាររបស់អគ្គលេខាធិការ និងអគ្គលេខាធិការដ្ឋានទាំងមូល

(ច) កំណត់ចំនួនបុគ្គលិកដែលត្រូវជ្រើសរើស លក្ខខណ្ឌការងារ ប្រាក់ឈ្នួល និងអត្ថប្រយោជន៍បន្ទាប់បន្សំ វិធានការវិន័យ និងលក្ខខណ្ឌផ្សេងៗទៀតដែលត្រូវយកមកអនុវត្តចំពោះបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន

(ឆ) បង្កើត អនុម័ត និងកែប្រែយន្តការ និងនីតិវិធីនានាសម្រាប់ពិនិត្យពិច័យលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនៃសំណុំរឿង ដែលគ្រប់គ្រងដោយ ម.ជ.ម.

(ជ) ពិនិត្យ និងតាមដានស្ថានភាពហិរញ្ញវត្ថុរបស់ ម.ជ.ម. ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយអគ្គលេខាធិការស្របតាមវិធានជាធរមាន ដែលអនុវត្តចំពោះដំណើរការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ ម.ជ.ម.

(ឈ) រៀបចំ និងបញ្ជូនឯកសារដូចខាងក្រោម ដើម្បីសុំការអនុម័តពីមហាសន្និបាតៈ

ឈ.១- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ជ.ម. នៃឆ្នាំហិរញ្ញវត្ថុមុន

ឈ.២- ថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំហិរញ្ញវត្ថុចរន្ត និងថវិកាសម្រាប់ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុបន្ទាប់ និង

(ញ) អនុវត្តសេចក្ដីសម្រេចនានារបស់មហាសន្និបាត។

២៥.២.ក្រុមប្រឹក្សាប្រតិបត្តិត្រូវរាយការណ៍ជូនមហាសន្និបាតអំពីសកម្មភាពប្រចាំឆ្នាំ និងសេចក្ដីសម្រេចនានារបស់ខ្លួន។

២៥.៣.ក្នុងការបំពេញតួនាទីដូចមានកំណត់ក្នុងប្រការ ២៥.១ ខាងលើ ក្រុមប្រឹក្សាប្រតិបត្តិអាចធ្វើការសម្រេចចាំបាច់នានាចំពោះកិច្ចការទាំងឡាយណាដែលមិនមែនជាសមត្ថកិច្ចរបស់មហាសន្និបាត ហើយសេចក្ដីសម្រេចនោះត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២៥.៤.ដើម្បីជួយដល់ការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិត្រូវបង្កើតគណៈកម្មាធិការតែងតាំង និងនីតិវិធី គណៈកម្មាធិការវិន័យ គណៈកម្មាធិការអប់រំ និងបណ្ដុះបណ្ដាល និងគណៈកម្មាធិការសមាជិកភាព ដែលមានតួនាទី និងសមាសភាពដូចមាន កំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនេះ។ ក្រុមប្រឹក្សាប្រតិបត្តិអាចបង្កើតគណៈកម្មាធិការផ្សេងៗទៀតតាមការចាំបាច់។

២៥.៥.ប្រសិនបើមហាសន្និបាតសម្រេចបដិសេធលុបចោលសេចក្ដីសម្រេចណាមួយរបស់ក្រុមប្រឹក្សាប្រតិបត្តិ ការបដិសេធលុបចោលនោះមិនត្រូវមានអានុភាពប្រតិសកម្មឡើយ។

## ប្រការ ២៦. ចំនួនសមាជិក និងសមាសភាពក្រុមប្រឹក្សាប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវមានចំនួនសេស មិនលើសពី ៧ (ប្រាំពីរ) រូប និងមិនត្រូវតិចជាង ៥ (ប្រាំ) រូបឡើយ។ មុនពេលបញ្ចប់អាណត្តិនីមួយៗ ដែលមានរយៈពេល ៣ (បី) ឆ្នាំ មហាសន្និបាតអាចសម្រេចកំណត់ចំនួនសមាជិកក្រុមប្រឹក្សាប្រតិបត្តិសម្រាប់អាណត្តិបន្ទាប់។

## ប្រការ ២៧. ការទូទាត់សងការចំណាយ និងប្រាក់ឧបត្ថម្ភ

សមាជិកក្រុមប្រឹក្សាប្រតិបត្តិមិនត្រូវទទួលបានប្រាក់ឈ្នួលឡើយ ប៉ុន្តែអាចទទួលបានប្រាក់ឧបត្ថម្ភ ឬការទូទាត់សងវិញ ចំពោះការចំណាយចាំបាច់នានាដែលបានធ្វើស្របតាមវិធានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

## ប្រការ ២៨. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

២៨.១.ក្រុមប្រឹក្សាប្រតិបត្តិត្រូវប្រជុំរៀងរាល់ខែ។ ក្នុងកិច្ចប្រជុំនីមួយៗរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំខែបន្ទាប់។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិអាចធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយ តាមរយៈសន្និសីទវីដេអូ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀត ជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន (ឬក្នុងទម្រង់រួមបញ្ចូលគ្នា)។

២៨.២.របៀបវារៈដែលត្រូវលើកមកពិភាក្សាសម្រាប់កិច្ចប្រជុំខែបន្ទាប់ត្រូវបញ្ជូនទៅសមាជិកទាំងអស់នៃក្រុមប្រឹក្សាប្រតិបត្តិ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទប្រជុំ។

២៨.៣.ក្នុងករណីគ្មានរបៀបវារៈចាំបាច់និងបន្ទាន់ ដែលត្រូវតែលើកយកមកពិភាក្សានៅកាលបរិច្ឆេទដែលបានកំណត់ទេ កិច្ចប្រជុំដែលបានគ្រោងទុកនោះអាចត្រូវបានលើកទៅខែបន្ទាប់ តាមការសម្រេចដោយសំឡេងភាគច្រើន ហាសិបភាគរយបូកមួយ (៥០%បូក១) របស់សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់។ ទោះបីក្នុងករណីណាក៏ដោយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣ (បី) ខែ។ ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិអាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទប្រជុំ។ ការជូនដំណឹងត្រូវរួមបញ្ចូលផងដែរនូវព័ត៌មានអំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ និងរបៀបវារៈ។

២៨.៤.កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាប្រតិបត្តិ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមួយរូបត្រូវមានសំឡេងឆ្នោតមួយសំឡេង។ សមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាប្រតិបត្តិ អាចអញ្ជើញបុគ្គលមួយរូប ឬច្រើនរូប រួមមានជាអាទិ៍អគ្គលេខាធិការ ឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬផ្នែកណាមួយនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ សម្រាប់គោលបំណងជាក់លាក់ណាមួយ។

២៨.៥.សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិដែលមិនអាចចូលរួមក្នុងកិច្ចប្រជុំណាមួយរបស់ក្រុមប្រឹក្សាប្រតិបត្តិអាចផ្តល់សិទ្ធិប្រទានដល់សមាជិកក្រុមប្រឹក្សាប្រតិបត្តិម្នាក់ទៀត ឱ្យតំណាងខ្លួនក្នុងកិច្ចប្រជុំនោះ និងបោះឆ្នោតក្នុងនាមខ្លួន។ សមាជិកម្នាក់ៗមិនអាចទទួលសិទ្ធិប្រទានពីសមាជិកក្រុមប្រឹក្សាប្រតិបត្តិម្នាក់ទៀតលើសពីមួយនោះទេ។ សិទ្ធិប្រទាននឹងត្រូវបានបញ្ជាក់ និងភ្ជាប់ក្នុងកំណត់ត្រានៃកិច្ចប្រជុំនោះ។

២៨.៦.ដើម្បីជៀសវាងការភ័ន្តច្រឡំ សមាជិកជានីតិបុគ្គលដែលជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិមិនចាំបាច់ធ្វើសិទ្ធិប្រទានទៅអ្នកតំណាងរបស់ខ្លួនឡើយ។

២៨.៧.កូរ៉ុមនៃកិច្ចប្រជុំ គឺវត្តមានយ៉ាងតិច ២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាប្រតិបត្តិ ដោយរាប់បញ្ចូលទាំងការចូលរួមដោយផ្ទាល់ ឬតាមរយៈសិទ្ធិប្រទាន។

ក្នុងករណីដែលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើឡើង ដោយមានការចូលរួមពីចម្ងាយ តាមរយៈសន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀត ជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន ឬក្នុងទម្រង់រួមបញ្ចូលគ្នាជាមួយនឹងការចូលរួមដោយផ្ទាល់ ស្របតាមប្រការ ២៨.១ វត្តមានរបស់សមាជិកក្រុមប្រឹក្សាប្រតិបត្តិចូលរួមដោយផ្ទាល់ ឬតាមរយៈសន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតទាំងនោះ ព្រមទាំងសិទ្ធិប្រទាននឹងត្រូវរាប់ សម្រាប់កំណត់កូរ៉ុមដូចមានតម្រូវក្នុងកថាខណ្ឌខាងលើ។

២៨.៨.ដើម្បីមានសុពលភាពអនុវត្ត រាល់សេចក្តីសម្រេចទាំងអស់របស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវសម្រេចដោយ សំឡេងគាំទ្រភាគច្រើនហាសិបភាគរយបូកមួយ (៥០%បូក១) នៃសមាជិកដែលចូលរួមកិច្ចប្រជុំដោយផ្ទាល់ និងតាមរយៈសិទ្ធិប្រទាន។ ក្នុងករណីដែលមានសំឡេងឆ្នោតស្មើគ្នា សំឡេងឆ្នោតរបស់ប្រធានត្រូវមានឧត្តមានុភាព។ ការបោះឆ្នោតត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬដោយការលើកដៃ ប៉ុន្តែការបោះឆ្នោតត្រូវធ្វើឡើងជាសម្ងាត់ ប្រសិនបើមានសមាជិកណាម្នាក់នៃក្រុមប្រឹក្សាប្រតិបត្តិស្នើសុំ។

ក្នុងករណីដែលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើឡើង ដោយមានការចូលរួមពីចម្ងាយ តាមរយៈសន្និសីទវីដេអូ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀត ជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន ឬក្នុងទម្រង់រួមបញ្ចូលគ្នាជាមួយនឹងការចូលរួមដោយផ្ទាល់ ស្របតាមប្រការ ២៨.១ ការបោះឆ្នោតត្រូវធ្វើឡើងតាមរយៈការលើកដៃ ឬតាមរយៈមធ្យោបាយបោះឆ្នោតអេឡិចត្រូនិច ដែលអាចធានាបាននូវសុច្ចរិតភាពនៃការបោះឆ្នោត។

២៨.៩.ក្នុងករណីសមាជិកទាំងអស់នៃក្រុមប្រឹក្សាប្រតិបត្តិមានវត្តមានដោយផ្ទាល់ក្នុងអង្គប្រជុំ កិច្ចប្រជុំអាចៈ

(ក) ធ្វើសេចក្តីសម្រេចលើបញ្ហាដែលមិនត្រូវបានដាក់ក្នុងរបៀបវារៈ ដែលត្រូវលើកមកពិភាក្សាក្នុងកិច្ចប្រជុំ និង

(ខ) ធ្វើសេចក្តីសម្រេចបើទោះបីជាកិច្ចប្រជុំមិនត្រូវកោះអញ្ជើញត្រឹមត្រូវតាមនីតិវិធីជាធរមាន។

២៨.១០.សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមិនអាចត្រូវបានធ្វើឡើង ឬអនុម័តក្រៅកិច្ចប្រជុំ លើកលែងតែសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមប្រឹក្សាប្រតិបត្តិ។ សេចក្តីសម្រេចអាចត្រូវបានធ្វើឡើងជាច្រើនច្បាប់។ សេចក្តីសម្រេចមួយច្បាប់ៗដូចៗគ្នារួមបញ្ចូលគ្នាបង្កើតជាច្បាប់ដើមនៃសេចក្តីសម្រេចតែមួយរបស់ក្រុមប្រឹក្សាប្រតិបត្តិ។

២៨.១១.កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធាន ឬរបស់អនុប្រធានក្នុងករណីដែលប្រធានអវត្តមាន។

២៨.១២.ប្រធានត្រូវតែងតាំងបុគ្គលយ៉ាងតិចមួយរូបឱ្យកត់ត្រាកំណត់ហេតុប្រជុំ។ កំណត់ហេតុប្រជុំត្រូវមាន បញ្ជាក់កាលបរិច្ឆេទ ពេលវេលា ទីកន្លែងប្រជុំ ឈ្មោះអ្នកចូលរួមដែលមានវត្តមាន និងសិទ្ធិប្រទានដែលបានទទួល និងសេចក្តីសម្រេចដែលត្រូវបានអនុម័ត ឬបដិសេធដោយត្រូវមានបញ្ជាក់ផងដែរនូវចំនួនសំឡេងឆ្នោតសម្រាប់សេចក្តីសម្រេចនោះ។ កំណត់ហេតុប្រជុំនឹងត្រូវលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំបន្ទាប់ និងក្រោយពីមានការកែតម្រូវ និងឯកភាពរួចហើយ កំណត់ហេតុប្រជុំនោះត្រូវចុះហត្ថលេខាដោយប្រធានកិច្ចប្រជុំ និងអ្នកកត់ត្រាកំណត់ហេតុប្រជុំ។

## ប្រការ ២៩. ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រតិបត្តិ

២៩.១.មហាសន្និបាតប្រចាំឆ្នាំត្រូវបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាប្រតិបត្តិចេញពីសមាជិករបស់ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត សម្រាប់អាណត្តិរយៈពេល ៣ (បី) ឆ្នាំ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមិនអាចបំពេញមុខងារក្នុងក្រុមប្រឹក្សាប្រតិបត្តិលើសពី ២ (ពីរ) អាណត្តិឡើយ។ សមាជិកទាំងអស់របស់ក្រុមប្រឹក្សាប្រតិបត្តិលើកលែងតែមុខតំណែងជាហេរញ្ញិក អាចត្រូវបានជ្រើសរើសសម្រាប់រយៈពេល ២ (ពីរ) អាណត្តិជាប់ៗគ្នា។

២៩.២.សមាជិកជាមជ្ឈត្តករ ឬសមាជិកជានីតិបុគ្គលអាចឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិបាន ប្រសិនបើសមាជិកនោះបំពេញលក្ខណសម្បត្តិសម្រាប់ការតែងតាំងឱ្យឈរឈ្មោះបោះឆ្នោតដូចខាងក្រោម៖

(ក) បេក្ខជនត្រូវបានតែងតាំងដោយសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតចំនួន ២ (ពីរ) រូប

(ខ) បេក្ខជនដែលត្រូវបានតែងតាំងត្រូវយល់ព្រមចំពោះការតែងតាំងនោះ

(គ) ការតែងតាំង និងការយល់ព្រមចំពោះការតែងតាំងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ភាគីទាំង ៣ (បី) ដែលពាក់ព័ន្ធនិង

(ឃ) សមាជិក ម.ជ.ម. ម្នាក់ៗគ្មានសិទ្ធិតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោតលើសពីមួយរូបឡើយ។

(ង) សមាជិក ម.ជ.ម ដែលបានតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោតរួចហើយ មិនអាចឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតឡើយ ហើយបេក្ខជនដែលបានឈរឈ្មោះបោះឆ្នោតរួចហើយ ក៏មិនអាចតែងតាំងបេក្ខជនផ្សេងទៀតដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតដែរ។

២៩.៣.ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទមហាសន្និបាតប្រចាំឆ្នាំដែលការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាប្រតិបត្តិនឹងត្រូវធ្វើឡើង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបង្កើតគណៈកម្មការរៀបចំការបោះឆ្នោត កំណត់ និងជូនដំណឹងដល់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ដែលមានសិទ្ធិបោះឆ្នោតអំពី៖

(ក) កាលបរិច្ឆេទនៃការតែងតាំងបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយមានភ្ជាប់ទម្រង់ឯកសារសម្រាប់ការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត

(ខ) កាលបរិច្ឆេទនៃការបោះឆ្នោត ដែលជាកាលបរិច្ឆេទនៃមហាសន្និបាតប្រចាំឆ្នាំ មិនត្រូវតិចជាង២១ (ម្ភៃមួយ) ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត និង

(គ) ពេលវេលា និងទីកន្លែង ដែលមហាសន្និបាតប្រចាំឆ្នាំ និងការបោះឆ្នោតត្រូវរៀបចំ។

២៩.៤.ឯកសារនៃការតែងតាំងត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋានត្រឹមកាលបរិច្ឆេទនៃការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវពិនិត្យមើលឯកសារនៃការតែងតាំងបេក្ខជន និងសម្រេចពីភាពត្រឹមត្រូវនៃឯកសារនោះដោយយោងតាមប្រការ ២៩.២ ខាងលើ។ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃធ្វើការ ក្រុមប្រឹក្សាប្រតិបត្តិត្រូវអនុញ្ញាតឱ្យមានការកែតម្រូវចំពោះឯកសារនៃការតែងតាំងដែលមិនស្របតាមប្រការ ២៩.២ ខាងលើ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវបដិសេធឯកសារនៃការតែងតាំងដែលបានកែតម្រូវហើយ ប៉ុន្តែនៅតែមានភាពមិនសមស្រប ដោយភ្ជាប់ជាមួយសេចក្តីពន្យល់ទៅអ្នកសុំការទទួលស្គាល់ការតែងតាំង និងអ្នកដែលត្រូវបានតែងតាំង។

២៩.៥.ប្រសិនបើបេក្ខជនដែលបានបំពេញលក្ខណសម្បត្តិសម្រាប់ការតែងតាំងមានចំនួនតិចជាង ឬស្មើនឹងចំនួនតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិដែលបានកំណត់ ដោយមហាសន្និបាតស្របតាមប្រការ ២៦ ខាងលើ ការតែងតាំងបេក្ខជននឹងត្រូវចាប់ផ្តើមសារជាថ្មីសម្រាប់រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ស្របតាមនីតិវិធីនៃការតែងតាំង និងលក្ខណសម្បត្តិដែលបានកំណត់ខាងលើ។ ប្រសិនបើនៅកាលបរិច្ឆេទតែងតាំងបេក្ខជនសារជាថ្មី ចំនួនបេក្ខជនដែលបានបំពេញលក្ខណសម្បត្តិនៃការតែងតាំងនៅតែមានចំនួនតិចជាង ឬស្មើនឹងចំនួនតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិ បេក្ខជនទាំងនោះនឹងត្រូវបានជ្រើសតាំងជាស្វ័យប្រវត្តិ។ នៅក្នុងករណីនេះ និងស្របតាមប្រការ ៣០.៣ ខាងក្រោម មហាសន្និបាតត្រូវតែងតាំង និងជ្រើសតាំងបេក្ខជនបន្ថែមដើម្បីបង្គ្រប់តំណែងទាំងអស់ក្នុងក្រុមប្រឹក្សាប្រតិបត្តិ។

២៩.៦.ប្រសិនបើចំនួនបេក្ខជនដែលបានបំពេញលក្ខណសម្បត្តិសម្រាប់ការតែងតាំងមានចំនួនច្រើនជាងចំនួនតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិដែលមានសម្រាប់ការបោះឆ្នោត ក្រុមប្រឹក្សាប្រតិបត្តិត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជន និងឈ្មោះអ្នកតំណាងសម្រាប់បេក្ខភាពជានីតិបុគ្គលទៅសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតទាំងអស់យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទបោះឆ្នោត។

២៩.៧.ការបោះឆ្នោតនៃក្រុមប្រឹក្សាប្រតិបត្តិត្រូវរៀបចំក្នុងកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំតាមរយៈការបោះឆ្នោតជាសម្ងាត់លើសន្លឹកឆ្នោតដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន។

២៩.៨.វិធានសម្រាប់ការបោះឆ្នោតដូចខាងក្រោមនឹងត្រូវអនុវត្តក្នុងកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំ៖

(ក) ក្នុងសន្លឹកឆ្នោតនីមួយៗត្រូវរៀបតាមលំដាប់ព្យញ្ជនៈនៃឈ្មោះរបស់បេក្ខជនទាំងអស់ ដែលសរសេរជាព្យញ្ជនៈឡាតាំងតម្រៀបទន្ទឹមនឹងឈ្មោះជាភាសាខ្មែរ។ សម្រាប់បេក្ខជនជានីតិបុគ្គលត្រូវសរសេរឈ្មោះរបស់នីតិបុគ្គលព្រមជាមួយឈ្មោះរបស់អ្នកតំណាង។

(ខ) សមាជិកនៃ ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោត រួមបញ្ចូលទាំងបេក្ខជនឈរឈ្មោះអាចបោះឆ្នោតបានមួយសំឡេងសម្រាប់តំណែងនីមួយៗក្នុងក្រុមប្រឹក្សាប្រតិបត្តិ។

(គ) គ្មានសមាជិករបស់ ម.ជ.ម. រូបណាអាចបោះឆ្នោតបានច្រើនជាងមួយសំឡេងឱ្យទៅបេក្ខជន ណាម្នាក់នោះទេ។

(ឃ) ការបោះឆ្នោតដោយសិទ្ធិប្រទានត្រូវបានអនុញ្ញាតក្នុងលក្ខខណ្ឌថាសិទ្ធិប្រទានត្រូវបានផ្តល់ទៅសមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតម្នាក់ទៀត។ សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតមានសិទ្ធិទទួលយកសិទ្ធិប្រទានតែមួយប៉ុណ្ណោះ។ សិទ្ធប្រទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងកត់ត្រាក្នុងកំណត់ហេតុប្រជុំ។

(ង) គណៈកម្មការរៀបចំការបោះឆ្នោតត្រូវហៅឈ្មោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិបោះឆ្នោត តាមលំដាប់ឈ្មោះដែលសរសេរជាភាសាឡាតាំងឱ្យឡើងបោះឆ្នោត ។

(ច) ដើម្បីបោះឆ្នោត សមាជិក ម.ជ.ម. ដែលមានសិទ្ធិបោះឆ្នោតត្រូវដាក់សញ្ញា () ឬ សញ្ញា (×) ក្នុងប្រអប់ការេ ដែលដាក់សម្រាប់ឈ្មោះបេក្ខជននីមួយៗ។

(ឆ) រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបោះឆ្នោតត្រូវដាក់សន្លឹកឆ្នោតរបស់ពួកគេនៅក្នុងប្រអប់ឆ្នោតបិទជិត។

២៩.៩.គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវរាប់ចំនួនសំឡេងឆ្នោតដែលបានបោះឱ្យបេក្ខជននីមួយៗ និងកត់ត្រាចំនួនសំឡេងឆ្នោតទាំងនោះនៅពីក្រោយឈ្មោះបេក្ខជននីមួយក្នុងទម្រង់ ដែលអគ្គលេខាធិការដ្ឋានបានកំណត់។ វិធានខាងក្រោមត្រូវអនុវត្ត៖

(ក) ប្រសិនបើសន្លឹកឆ្នោតបង្ហាញសំឡេងឆ្នោតច្រើនជាងតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិដែលត្រូវបានដាក់ឱ្យបោះឆ្នោត សំឡេងឆ្នោតទាំងអស់នៃសន្លឹកឆ្នោតនោះត្រូវបានចាត់ទុកថាឥតបានការ។

(ខ) ប្រសិនបើសន្លឹកឆ្នោតបង្ហាញសំឡេងឆ្នោតតិចជាងតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិដែលត្រូវបានដាក់ឱ្យបោះឆ្នោត សំឡេងឆ្នោតទាំងអស់នៃសន្លឹកឆ្នោតនោះត្រូវមានសុពលភាព និងត្រូវបានរាប់។

(គ) សន្លឹកឆ្នោតដែលត្រូវបានគូសសញ្ញាផ្សេងក្រៅពីសញ្ញាកំណត់ក្នុងប្រការ ២៩.៨(ច) ខាងលើ ត្រូវចាត់ទុកថាឥតបានការ។

២៩.១០.គណៈកម្មការរៀបចំការបោះឆ្នោតត្រូវវាយឈ្មោះបេក្ខជនតាមលំដាប់ព្យញ្ជនៈនៃភាសាឡាតាំង។ បេក្ខជន ដែលបានទទួលសំឡេងឆ្នោតច្រើនបំផុត និងដែលមានចំនួនស្មើនឹងចំនួនតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិត្រូវបានចាត់ទុកថាបានជាប់ឆ្នោត។

ប្រសិនបើបញ្ជីនៃបេក្ខជនដែលជាប់ឆ្នោតមិនអាចកំណត់បាន ដោយសារតែមានបេក្ខជន ២ (ពីរ) ឬច្រើនរូប បានទទួលសំឡេងឆ្នោតស្មើគ្នា កិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំដដែលនោះ ត្រូវរៀបចំការបោះឆ្នោតលើកទីពីរ សម្រាប់បេក្ខជនដែលទទួលបានសំឡេងឆ្នោតស្មើគ្នានោះ។ ប្រសិនបើបេក្ខជន នៅតែទទួលបានសំឡេងឆ្នោតស្មើគ្នាក្នុងការបោះឆ្នោតលើកទីពីរ បេក្ខជនដែលមានអាយុច្រើនជាងគេនឹងត្រូវបានជ្រើសរើស ចំពោះបេក្ខជនជានីតិបុគ្គល អាយុរបស់អ្នកតំណាង គឺជាកត្តាកំណត់។

គណៈកម្មការបោះឆ្នោតត្រូវប្រកាសលទ្ធផលការបោះឆ្នោតភ្លាមៗក្នុងកិច្ចប្រជុំមហាសន្និបាត និងបន្ទាប់មកត្រូវជូនដំណឹងទៅសមាជិកទាំងអស់របស់ ម.ជ.ម. ក៏ដូចជាសាធារណជនអំពីលទ្ធផលនេះ។

ស្របតាមវិធានស្តីពីការបោះឆ្នោតដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ សមាជិកក្រុមប្រឹក្សាប្រតិបត្តិ ដែលទើបត្រូវបានបោះឆ្នោតថ្មី ត្រូវចូលកាន់តំណែងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានការបញ្ជាក់ពីការបោះឆ្នោត។

២៩.១១.ក្រុមប្រឹក្សាប្រតិបត្តិអាចតែងតាំងគណៈកម្មការរៀបចំការបោះឆ្នោតឱ្យត្រួតពិនិត្យការតែងតាំងការឈរឈ្មោះ និងរៀបចំដំណើរការបោះឆ្នោត។ គណៈកម្មការបោះឆ្នោតដែលត្រូវបានតែងតាំង ត្រូវអនុម័តវិធានបោះឆ្នោត កំណត់អំពីនីតិវិធីនៃការតែងតាំងការឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាប្រតិបត្តិស្របតាមបទបញ្ជាផ្ទៃក្នុងនេះ។

## ប្រការ ៣០. ការបញ្ចប់សមាជិកភាពនៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ

៣០.១.សមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ ដែលជាសមាជិកជាមជ្ឈត្តករត្រូវចេញពីតំណែងរបស់ខ្លួននៅក្នុងករណីណាមួយដូចខាងក្រោម៖

(ក) ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ ឬសតិស្មារតី មិនអាចបំពេញតួនាទីរបស់ខ្លួនបាន

(ខ) ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(គ) អវត្តមានពីកិច្ចប្រជុំ ៣ (បី) ដងជាប់ៗគ្នាដោយគ្មានមូលហេតុសមរម្យ

(ឃ) ត្រូវបានប្រកាសក្ស័យធនដោយតុលាការ

(ង) បានសុំលាឈប់ជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ

(ច) លែងជាសមាជិក ម.ជ.ម. ឬ

(ឆ) បានទទួលមរណភាព។

៣០.២.សមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ ដែលជាសមាជិកជានីតិបុគ្គល ត្រូវចេញពីតំណែងរបស់ខ្លួន នៅក្នុងករណីណាមួយដូចខាងក្រោម៖

(ក) ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(ខ) អវត្តមានពីកិច្ចប្រជុំ ៣ (បី) ដងជាប់ៗគ្នាដោយគ្មានមូលហេតុសមរម្យ

(គ) ត្រូវបានប្រកាសក្ស័យធនដោយតុលាការ ឬត្រូវបានដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី

(ឃ) បានសុំលាឈប់ជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ

(ង) លែងជាអ្នកតំណាងរបស់សមាជិកជានីតិបុគ្គល ឬ

(ច) លែងជាសមាជិក ម.ជ.ម. ។

៣០.៣.ប្រសិនបើសមាជិកក្រុមប្រឹក្សាប្រតិបត្តិ បានបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងក្រុមប្រឹក្សាប្រតិបត្តិដោយមូលហេតុណាមួយ ប្រធានត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីជ្រើសតាំងសមាជិកថ្មីសម្រាប់ក្រុមប្រឹក្សាប្រតិបត្តិ។ ការបោះឆ្នោតជ្រើសតាំងសមាជិកថ្មីសម្រាប់ជំនួសតំណែងក្នុងក្រុមប្រឹក្សាប្រតិបត្តិដែលទំនេរនេះត្រូវធ្វើឡើងស្របតាមប្រការ ២៩។ សមាជិកថ្មីត្រូវបន្តតំណែងសម្រាប់រយៈពេលដែលនៅសល់នៃអាណត្តិរបស់សមាជិកក្រុមប្រឹក្សាប្រតិបត្តិមុន។

## ប្រការ ៣១. អាណត្តិ និងការបោះឆ្នោត

៣១.១.សមាសភាពរបស់ក្រុមប្រឹក្សាប្រតិបត្តិរួមមាន៖

(ក) ប្រធាន ១ (មួយ) រូប

(ខ) អនុប្រធាន ១ (មួយ) រូប

(គ) ហេរញ្ញិក ១ (មួយ) រូប និង

(ឃ) សមាជិក យ៉ាងច្រើន ៤ (បួន) រូប ។

មហាសន្និបាតត្រូវកំណត់ចំនួនសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិស្របតាមបញ្ញត្តិខាងលើ។ ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិគឺជាប្រធាន ម.ជ.ម. និងជាអ្នកតំណាងតាមផ្លូវច្បាប់របស់ ម.ជ.ម.។ អនុប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិត្រូវជួយការងាររបស់ប្រធាន និងជំនួសប្រធានក្នុងអំឡុងពេលដែលប្រធានអវត្តមាន។

ហេរញ្ញិកត្រូវត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់អគ្គលេខាធិការ ឬត្រូវផ្តល់សមត្ថកិច្ចដល់បុគ្គលិកអគ្គលេខាធិការដ្ឋានក្នុងការប្រមូលចំណូល និងចំណាយ និងត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់ ម.ជ.ម.។

៣១.២.សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសញ្ជាតិខ្មែរ។ ប្រធាន និងហេរញ្ញិកត្រូវមានសញ្ជាតិខ្មែរ។

៣១.៣.ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នាដោយក្រុមប្រឹក្សាប្រតិបត្តិចេញពីសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិក្នុងកិច្ចប្រជុំដំបូងនៃអាណត្តិ ៣ (បី) ឆ្នាំ ដែលក្រុមប្រឹក្សាប្រតិបត្តិត្រូវបានជ្រើសតាំង។

៣១.៤.ប្រធានត្រូវជ្រើសតាំងដោយសំឡេងភាគច្រើននៃសំឡេងឆ្នោតទាំងអស់ដែលបានបោះ។ ប្រសិនបើគ្មានបេក្ខជនរូបណាត្រូវបានជ្រើសតាំងទេ កិច្ចប្រជុំសម្រាប់ការបោះឆ្នោតលើកទីពីរត្រូវធ្វើឡើងក្នុងអំឡុងពេលមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ដោយមានតែបេក្ខជន ២ (ពីរ) រូបដែលទទួលបានសំឡេងឆ្នោតភាគច្រើនជាងគេ ឬបេក្ខជន ២ (ពីរ) ឬច្រើនរូប ដែលបានទទួលសំឡេងឆ្នោតស្មើគ្នាក្នុងការបោះឆ្នោតលើកទីមួយប៉ុណ្ណោះដែលមានសិទ្ធិឈរឈ្មោះសម្រាប់ការបោះឆ្នោតលើកទីពីរនេះ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតភាគច្រើនជាងគេក្នុងការបោះឆ្នោតលើកទីពីរនឹងត្រូវបានជ្រើសតាំង។ ប្រសិនបើមានបេក្ខជនទទួលបានសំឡេងឆ្នោតស្មើគ្នាក្នុងការបោះឆ្នោតលើកទីពីរ បេក្ខជនដែលមានអាយុច្រើនជាងគេនឹងត្រូវបានជ្រើសតាំង និងប្រសិនបើបេក្ខជននោះគឺជាសមាជិកជានីតិបុគ្គល អាយុរបស់អ្នកតំណាងគឺជាកត្តាកំណត់។

៣១.៥.អនុប្រធាន និងហេរញ្ញិកត្រូវជ្រើសតាំងដោយសំឡេងភាគច្រើននៃសំឡេងឆ្នោតទាំងអស់ដែលបានបោះ។ ក្នុងករណីដែលសំឡេងឆ្នោតស្មើគ្នា សមាជិកក្រុមប្រឹក្សាប្រតិបត្តិណាដែលមានអាយុច្រើនជាងគេនឹងត្រូវបានជ្រើសតាំង និងប្រសិនបើបេក្ខជនជាសមាជិកជានីតិបុគ្គល អាយុរបស់អ្នកតំណាងគឺជាកត្តាកំណត់។

៣១.៦.ប្រសិនបើតំណែងរបស់ប្រធាន អនុប្រធាន ឬហេរញ្ញិកក្លាយជាទំនេរដោយសារមូលហេតុណាមួយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវជ្រើសតាំងសមាជិកមួយរូបពីសមាជិករបស់ខ្លួនឱ្យកាន់តំណែងដែលទំនេរនោះស្របតាមនីតិវិធីនៃប្រការនេះ។ សមាជិកនោះត្រូវបន្តតំណែងដែលទំនេរនោះរហូតដល់ចប់អាណត្តិ។

ជំពូកទី ៦

# គណៈកម្មាធិការ

## ប្រការ ៣២. សមត្ថកិច្ចក្នុងការបង្កើតគណៈកម្មាធិការ

ក្រុមប្រឹក្សាប្រតិបត្តិអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការសម្រាប់បំពេញកិច្ចការ ឬគម្រោងនានាដោយសំឡេងភាគច្រើនហាសិបភាគរយបូកមួយ (៥០%បូក១)។ ក្រុមប្រឹក្សាប្រតិបត្តិ អាចកំណត់ ឬកែប្រែការរៀបចំរចនាសម្ព័ន្ធ និងតួនាទីរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការទាំងនោះ។

## ប្រការ ៣៣. បទប្បញ្ញត្តិទូទៅសម្រាប់គណៈកម្មាធិការ

៣៣.១.លើកលែងតែក្រុមប្រឹក្សាប្រតិបត្តិកំណត់ផ្សេងពីនោះ គណៈកម្មាធិការនីមួយៗត្រូវមានសមាជិក យ៉ាងតិច ៣ (បី) រូប និងសមាជិកបម្រុង ៣ (បី) រូប។ ចំនួនសមាជិករបស់គណៈកម្មាធិការនីមួយៗអាចត្រូវបានផ្លាស់ប្តូរប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិយល់ថាចាំបាច់។ សមាជិកបម្រុងរបស់គណៈកម្មាធិការនីមួយៗនឹងត្រូវបានអញ្ជើញតាមលក្ខណៈប្តូរវេន ដើម្បីជំនួសសមាជិកគណៈកម្មាធិការដែលមិនអាចបំពេញតួនាទីរបស់ខ្លួនបាន។

៣៣.២.សមាជិក និងសមាជិកបម្រុងរបស់គណៈកម្មាធិការនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សាប្រតិបត្តិ។ សមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការមួយមិនអាចជាសមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការមួយទៀតឡើយ។ ការតែងតាំងគណៈកម្មាធិការជានិច្ចកាលត្រូវមានសមាជិកជាមជ្ឈត្តករយ៉ាងតិចមួយរូប និងស្របតាមអត្តិភាពជាក់ស្តែងរបស់សមាជិកជានីតិបុគ្គល ក្រុមប្រឹក្សាប្រតិបត្តិត្រូវព្យាយាមតែងតាំងសមាជិកជានីតិបុគ្គលយ៉ាងតិចមួយរូប។

៣៣.៣.អាណត្តិរបស់សមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការមានរយៈពេល ៣ (បី) ឆ្នាំ។ សមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការ មិនអាចបម្រើការលើសពី ២ (ពីរ) អាណត្តិជាប់ៗគ្នា នៅក្នុងគណៈកម្មាធិការតែមួយឡើយ។ សមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការ ដែលបម្រើការចំនួន ២ (ពីរ) អាណត្តិជាប់ៗគ្នានៅក្នុងគណៈកម្មាធិការតែមួយ ត្រូវមិនបម្រើការមួយអាណត្តិនៅក្នុងគណៈកម្មាធិការនានារបស់ ម.ជ.ម. មុននឹងអាចត្រូវបានតែងតាំងសារជាថ្មី។

៣៣.៤.សមាជិក និងសមាជិកបម្រុងរបស់គណៈកម្មាធិការនីមួយៗ នឹងត្រូវបានផ្លាស់ប្តូរឆ្លាស់គ្នា ដោយសមាជិក ឬសមាជិកបម្រុងយ៉ាងតិច ២ (ពីរ) រូប ប៉ុន្តែមិនត្រូវមានការផ្លាស់ប្តូរសមាជិក ឬសមាជិកបម្រុងលើសពី ៤ (បួន) រូបក្នុងមួយឆ្នាំនោះទេ លើកលែងតែត្រូវបានកំណត់ផ្សេងដោយក្រុមប្រឹក្សាប្រតិបត្តិ។

៣៣.៥.សមាជិករបស់គណៈកម្មាធិការនីមួយៗត្រូវជ្រើសតាំងលេខាម្នាក់ពីក្នុងចំណោមសមាជិកទាំងអស់របស់ខ្លួន។ ប្រធានរបស់គណៈកម្មាធិការទាំងអស់ត្រូវជាសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ លើកលែងតែប្រធាននៃគណៈកម្មាធិការតែងតាំង និងនីតិវិធី ដែលត្រូវតែជាប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ។ គណៈកម្មាធិការនីមួយៗត្រូវរក្សាទុកកំណត់ត្រានៃការប្រជុំ និងសេចក្តីសម្រេចទាំងអស់របស់ខ្លួនដោយបង្ហាញមូលហេតុ ហើយគណៈកម្មាធិការនីមួយៗត្រូវបញ្ជូនច្បាប់ចម្លងនៃកំណត់ត្រាទាំងនោះទៅក្រុមប្រឹក្សាប្រតិបត្តិ។

៣៣.៦.សមាជិក និងសមាជិកបម្រុងនៃគណៈកម្មាធិការនីមួយៗត្រូវស្ថិតនៅក្រោមកាតព្វកិច្ចដ៏តឹងរ៉ឹង ក្នុងការបង្ហាញទៅក្រុមប្រឹក្សាប្រតិបត្តិ អំពីទំនាស់ផលប្រយោជន៍នានាដែលអាចមានពាក់ព័ន្ធនឹងការបំពេញតួនាទី ឬភារកិច្ចរបស់ខ្លួនក្នុងគណៈកម្មាធិការ។ សមាជិក និងសមាជិកបម្រុងត្រូវដកខ្លួនចេញពីការធ្វើសេចក្តីសម្រេចណាដែលអាចនាំឱ្យមានភាពលម្អៀង។

៣៣.៧.ក្រុមប្រឹក្សាប្រតិបត្តិអាចដកសមាជិក ឬសមាជិកបម្រុងណាម្នាក់ចេញពីគណៈកម្មាធិការណាមួយយោងតាមយោបល់របស់គណៈកម្មាធិការវិន័យ ដោយមូលហេតុណាមួយជាពិសេសពាក់ព័ន្ធនឹងភាពសុចរិតនៃសកម្មភាពរបស់សមាជិក ឬសមាជិកបម្រុងក្នុងតួនាទីជាសមាជិកឬសមាជិកបម្រុងនៃគណៈកម្មាធិការ។ ការខកខានក្នុងការបង្ហាញអំពីទំនាស់ផលប្រយោជន៍គឺជាមូលដ្ឋានមួយសម្រាប់ការដកចេញនេះ។

៣៣.៨.ប្រសិនបើសមាជិក ឬសមាជិកបម្រុងរបស់គណៈកម្មាធិការបានបាត់បង់តំណែងរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិត្រូវតែងតាំងសមាជិក ឬសមាជិកបម្រុងថ្មីក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទដែលសមាជិក ឬសមាជិកបម្រុងត្រូវបានបាត់បង់តំណែង។

៣៣.៩.សេចក្តីសម្រេចរបស់គណៈកម្មាធិការត្រូវធ្វើឡើងដោយសំឡេងភាគច្រើននៃសមាជិកទាំងអស់របស់ខ្លួន។ សមាជិក និងសមាជិកបម្រុង មិនអាចធ្វើសិទ្ធិប្រទានឡើយ។

៣៣.១០.ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់វិធានបន្ថែមពាក់ព័ន្ធនឹងការប្រតិបត្តិ និងនីតិវិធីសម្រាប់ធ្វើការរបស់គណៈកម្មាធិការនីមួយៗ។

## ប្រការ ៣៤. ការបង្កើត និងតួនាទីរបស់គណៈកម្មាធិការ

៣៤.១.គណៈកម្មាធិការខាងក្រោមត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលការងាររបស់ក្រុមប្រឹក្សាប្រតិបត្តិ៖

(ក) គណៈកម្មាធិការតែងតាំង និងនីតិវិធី

(ខ) គណៈកម្មាធិការវិន័យ

(គ) គណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាល និង

(ឃ) គណៈកម្មាធិការសមាជិកភាព។

៣៤.២.គណៈកម្មាធិការតែងតាំង និងនីតិវិធីត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

(ក) សម្រេចតែងតាំងមជ្ឈត្តករស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.

(ខ) សម្រេចលើការតវ៉ាពាក់ព័ន្ធនឹងការកំណត់យុត្តាធិការរបស់ ម.ជ.ម. ស្របតាមវិធានស្តីពីមជ្ឈត្តការ

(គ) សម្រេចលើសំណើសុំដំណើរការនីតិវិធីពន្លឿនស្របតាមវិធានស្តីពីមជ្ឈត្តការ

(ឃ) សម្រេចលើសំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ស្របតាមវិធានស្តីពីមជ្ឈត្តការ

(ង) តាមសំណើរបស់ក្រុមប្រឹក្សាប្រតិបត្តិ ផ្តល់យោបល់ចំពោះកិច្ចការនានាដែលពាក់ព័ន្ធនឹងដំណើរការនៃការតែងតាំងមជ្ឈត្តករស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. និង

(ច) បំពេញតួនាទីផ្សេងទៀតដែលក្រុមប្រឹក្សាប្រតិបត្តិស្នើឡើង។

៣៤.៣.គណៈកម្មាធិការវិន័យត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

(ក) ផ្តល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិពាក់ព័ន្ធនឹងប្រការ ១៩ និងប្រការ ៣០ ខាងលើ និងវិធានផ្សេងៗរបស់ ម.ជ.ម. ពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មលើសមាជិករបស់ ម.ជ.ម.

(ខ) ផ្តល់យោបល់ចំពោះកិច្ចការនានាដែលពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មតាមសំណើរបស់ក្រុមប្រឹក្សាប្រតិបត្តិ និង

(គ) បំពេញតួនាទីផ្សេងទៀតដែលក្រុមប្រឹក្សាប្រតិបត្តិស្នើឡើង។

៣៤.៤.គណៈកម្មាធិការអប់រំ និងបណ្ដុះបណ្ដាលត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

(ក) ផ្ដល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយទាក់ទងនឹងការអប់រំ និងកម្មវិធីបណ្ដុះបណ្ដាល រួមទាំងការអភិវឌ្ឍវិជ្ជាជីវៈដំបូង និងបន្តរបស់សមាជិក ម.ជ.ម. និងសមាជិកគាំទ្រស្របតាមច្បាប់ស្ដីពីមជ្ឈត្តការពាណិជ្ជកម្ម អនុក្រឹត្យលេខ ១២៤ និងវិធាន ជាធរមានផ្សេងៗ

(ខ) ផ្ដល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិពាក់ព័ន្ធនឹងការទទួលស្គាល់ស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម កម្មវិធីអប់រំ និងកម្មវិធីបណ្ដុះបណ្ដាលនានា និង

(គ) បំពេញតួនាទីផ្សេងទៀតដែលក្រុមប្រឹក្សាប្រតិបត្តិស្នើឡើង។

៣៤.៥.គណៈកម្មាធិការសមាជិកភាពត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

(ក) ពិនិត្យមើលពាក្យសុំចុះបញ្ជីសមាជិកភាពតាមបទបញ្ជាផ្ទៃក្នុងនេះ និងបញ្ជូនពាក្យសុំនេះ ព្រមជាមួយយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិ

(ខ) តាមសំណើរបស់ក្រុមប្រឹក្សាប្រតិបត្តិ ផ្ដល់យោបល់ចំពោះកិច្ចការនានាពាក់ព័ន្ធនឹងដំណើរការសុំចុះបញ្ជីសមាជិកភាពក្រោមបទបញ្ជាផ្ទៃក្នុងនេះ និង

(គ) បំពេញតួនាទីផ្សេងទៀតដែលក្រុមប្រឹក្សាប្រតិបត្តិស្នើឡើង។

ជំពូកទី ៧

# ការរក្សាការសម្ងាត់របស់ ម.ជ.ម.

**ប្រការ ៣៥. កាតព្វកិច្ចរក្សាការសម្ងាត់**

លើកលែងតែមានការកំណត់ផ្សេងដោយក្រុមប្រឹក្សាប្រតិបត្តិ រាល់កិច្ចការ និងសកម្មភាពរបស់ ម.ជ.ម. ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះត្រូវរក្សាជាការសម្ងាត់ ហើយត្រូវគោរពដោយបុគ្គល គ្រប់រូបដែលបានចូលរួមក្នុងកិច្ចការ និងសកម្មភាពនោះទោះក្នុងឋានៈអ្វីក៏ដោយ។

**ប្រការ ៣៦. បុគ្គលចូលរួមក្នុងកិច្ចការ និងសកម្មភាពរបស់ ម.ជ.ម.**

បុគ្គលចូលរួមក្នុងកិច្ចការ និងសកម្មភាពរបស់ ម.ជ.ម. សំដៅដល់បុគ្គល ដែលចូលរួមក្នុងកិច្ចការ និងសកម្មភាពរបស់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ អគ្គលេខាធិការ បុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន សមាជិកទាំងអស់របស់គណៈកម្មាធិការនីមួយៗ និងបុគ្គលគ្រប់រូប រួមទាំងរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចការ និងសកម្មភាពរបស់ ម.ជ.ម.។

ជំពូកទី ៨

# ក្រុមប្រឹក្សាពិគ្រោះយោបល់

## ប្រការ ៣៧. ក្រុមប្រឹក្សាពិគ្រោះយោបល់ គោលបំណង និងតួនាទី

៣៧.១.ម.ជ.ម. ត្រូវមានក្រុមប្រឹក្សាពិគ្រោះយោបល់។ ក្រុមប្រឹក្សាពិគ្រោះយោបល់មានតួនាទីផ្ដល់ព័ត៌មាន និងយោបល់ជំនាញទៅ ម.ជ.ម. សម្រាប់បញ្ហាពាក់ព័ន្ធនានា ការអភិវឌ្ឍ និងនិន្នាការ រួមបញ្ចូលទាំងវិធានមជ្ឈត្តការអន្តរជាតិ គោលនយោបាយ និងទម្លាប់អនុវត្តល្អៗ ច្បាប់ជាតិនិងអន្តរជាតិ និងយន្តការដោះស្រាយវិវាទក្រៅផ្លូវតុលាការ និងទម្លាប់អនុវត្តផ្នែកពាណិជ្ជកម្ម ការអភិវឌ្ឍស្ថាប័ន និងការគ្រប់គ្រង ព្រមទាំងការបណ្ដុះបណ្ដាល និងការអភិវឌ្ឍវិជ្ជាជីវៈ។

៣៧.២.ក្រុមប្រឹក្សាពិគ្រោះយោបល់អាចផ្ដល់យោបល់របស់ខ្លួនស្របតាមសំណូមពររបស់ក្រុមប្រឹក្សាប្រតិបត្តិ។ ក្រុមប្រឹក្សាពិគ្រោះយោបល់មានតួនាទីត្រឹមតែផ្ដល់យោបល់ដល់ ម.ជ.ម. ប៉ុន្តែមិនទទួលខុសត្រូវចំពោះការអនុវត្តសកម្មភាពនានារបស់ ម.ជ.ម. ឡើយ។

៣៧.៣.តាមសំណូមពររបស់ក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាពិគ្រោះយោបល់អាចផ្ដល់ជំនួយផ្នែកបច្ចេកទេស និងផ្នែកទំនាក់ទំនងសាធារណៈ ឬបំពេញតួនាទីផ្សេងទៀតដែលអាចត្រូវបានកំណត់ក្នុងកម្រិតដែលតួនាទីបន្ថែមនោះស្របតាមកម្មវត្ថុរបស់ ម.ជ.ម.។

## ប្រការ ៣៨. សមាជិកភាព និងកិច្ចប្រជុំ

៣៨.១.ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិអាចអញ្ជើញរូបវន្តបុគ្គលជាតិ ឬអន្តរជាតិ ដែលមានកិត្តិយស និងបទពិសោធន៍សមរម្យ និងជំនាញក្នុងវិស័យនានាដែលពាក់ព័ន្ធឱ្យបំពេញតួនាទីជាទីប្រឹក្សាដែលជាសមាជិកនៃក្រុមប្រឹក្សាពិគ្រោះយោបល់។

៣៨.២.ផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឥតគិតកម្រៃ សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់អាចស្នើផ្តល់ជំនាញ និងយោបល់ឯកទេសរបស់ខ្លួនដោយឡែក ឬជារួមទៅ ម.ជ.ម.។ ចំណាយសម្រាប់ការធ្វើដំណើរ និងចំណាយសមហេតុផលផ្សេងទៀតអាចត្រូវបានទូទាត់សងវិញទៅសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ ប្រសិនបើមានការឯកភាពទុកជាមុនពីក្រុមប្រឹក្សាប្រតិបត្តិ។

៣៨.៣.សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ ដែលមានបំណងលាឈប់ពីក្រុមប្រឹក្សាពិគ្រោះយោបល់ត្រូវ បញ្ជូនលិខិតលាឈប់ទៅក្រុមប្រឹក្សាប្រតិបត្តិ។

៣៨.៤.ក្រុមប្រឹក្សាប្រតិបត្តិ ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ ឬសន្និសីទតាមទូរស័ព្ទ អាចកោះហៅបើកកិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់ទាំងមូល ឬផ្នែកណាមួយដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាសមស្រប ឬចាំបាច់។ កិច្ចប្រជុំនោះត្រូវសម្របសម្រួល និងស្ថិតក្រោមអធិបតីភាពរបស់សមាជិកក្រុមប្រឹក្សាប្រតិបត្តិណាម្នាក់ ឬអគ្គលេខាធិការ។

ជំពូកទី ៩

# ការទទួលស្គាល់ស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស

## ប្រការ ៣៩. ស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស

៣៩.១.ស្របតាមបញ្ញត្តិមាត្រា ២៩ នៃអនុក្រឹត្យលេខ ១២៤ បទបញ្ជាផ្ទៃក្នុង និងវិធានផ្សេងៗរបស់ ម.ជ.ម. តាមរយៈការផ្តួចផ្តើមរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិអាចទទួលស្គាល់ស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស ដោយឈរលើមូលដ្ឋានណាមួយដូចខាងក្រោម៖

(ក) អត្ថិភាព និងប្រតិបត្តិការរបស់ស្ថាប័នជាមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលមានរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ មុនកាលបរិច្ឆេទដាក់សំណើ និងក្នុងអំឡុងពេលដប់ (១០) ឆ្នាំ នោះ មជ្ឈមណ្ឌលត្រូវធ្លាប់រៀបចំ ឬសម្របសម្រួលដំណើរការមជ្ឈត្តការយ៉ាងតិច ៥០ (ហាសិប) សំណុំរឿងវិវាទ

(ខ) ដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាប្រតិបត្តិ ចំពោះករណីដែលមានការទទួលស្គាល់គ្នាទៅវិញទៅមកដែលស្នើឡើងដោយមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេសណាមួយ ឬ

(គ) ដោយឈរលើមូលដ្ឋានណាមួយផ្សេងទៀត ដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាចាំបាច់សម្រាប់ករណីនីមួយៗ។

៣៩.២.ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិដឹងថាស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេសណាមួយ លែងមានលក្ខណសម្បត្តិដូចមានកំណត់ក្នុងប្រការ ៣៩.១ ខាងលើ ឬដោយមូលហេតុផ្សេងទៀត ដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាសមរម្យ ក្រុមប្រឹក្សាប្រតិបត្តិត្រូវដកហូតការទទួលស្គាល់នោះវិញ។

៣៩.៣.ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវរក្សាទុកបញ្ជីឈ្មោះមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេស ដែល ម.ជ.ម. បានទទួលស្គាល់។ ប្រសិនបើ ម.ជ.ម. ដកហូតការទទួលស្គាល់ចំពោះស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មបរទេសណាមួយ ក្រុមប្រឹក្សាប្រតិបត្តិត្រូវលុបឈ្មោះស្ថាប័ននោះចេញពីបញ្ជី។

## ជំពូកទី ១០

# សមត្ថកិច្ចក្នុងការតំណាង ម.ជ.ម.

### ប្រការ ៤០. សមត្ថកិច្ចក្នុងការតំណាង និងការចងកាតព្វកិច្ចចំពោះ ម.ជ.ម.

៤០.១. មានតែបុគ្គលដូចមានរៀបរាប់ក្នុងករណីនីមួយៗខាងក្រោមប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុង ការតំណាង និងចងកាតព្វកិច្ចចំពោះ ម.ជ.ម.៖

(ក) តាមរយៈសេចក្ដីសម្រេចដោយសំឡេងហាសិបបូកមួយ (៥០%បូកមួយ) នៃក្រុមប្រឹក្សាប្រតិបត្តិ ប្រធានត្រូវមានសមត្ថកិច្ចក្នុងការតំណាង និងចងកាតព្វកិច្ចចំពោះ ម.ជ.ម. នៅលើគ្រប់កិច្ចការទាំងអស់។

(ខ) ម.ជ.ម. នឹងត្រូវបានចងកាតព្វកិច្ចតាមរយៈការចុះហត្ថលេខារួមគ្នារបស់អគ្គលេខាធិការ និងសមាជិកនៃអគ្គលេខាធិការដ្ឋាន ដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ចំពោះករណីដូចខាងក្រោម៖

ខ.១-ការបង្កើតឱ្យមានកាតព្វកិច្ច ឬកិច្ចសន្យាណាមួយ ឬស៊េរីនៃកាតព្វកិច្ច ឬកិច្ចសន្យាដែលពាក់ព័ន្ធ ដែលមានតម្លៃជាទឹកប្រាក់សរុបមិនលើសពីទំហំកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ឬតម្លៃស្មើនឹងរូបិយវត្ថុផ្សេងទៀត ដូចមានចែងក្នុងសេចក្ដីសម្រេចដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ។

ខ.២-ការចំណាយណាមួយ ដែលមិនលើសពីទំហំកំណត់ ដោយក្រុមប្រឹក្សាប្រតិបត្តិ ឬតម្លៃស្មើនឹងរូបិយវត្ថុផ្សេងទៀត ដូចមានចែងក្នុងសេចក្ដីសម្រេចដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ។

គ្មានការបំបែក ឬការបែងចែកប្រតិបត្តិការ ឬកិច្ចសន្យានានាណាមួយ អាចប៉ះពាល់ដល់អានុភាពនៃការអនុវត្តបញ្ញត្តិនានាខាងលើឡើយ។

៤០.២. ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមប្រឹក្សាប្រតិបត្តិ បុគ្គលដែលមានសមត្ថកិច្ច ក្នុងការតំណាង ម.ជ.ម. ស្របតាមប្រការ ៤០.១ មានសិទ្ធិក្នុងការផ្តល់សមត្ថកិច្ចរបស់ខ្លួនទៅបុគ្គលម្នាក់ទៀតដែលជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ឬជាបុគ្គលិករបស់ ម.ជ.ម. ក្នុងរយៈពេលកំណត់ណាមួយសម្រាប់គោលបំណងជាក់លាក់ណាមួយ ។

៤០.៣. ក្រុមប្រឹក្សាប្រតិបត្តិអាចមោឃភាពកាតព្វកិច្ច ឬកិច្ចសន្យា ឬការបង់ប្រាក់ណាមួយដែលធ្វើឡើងក្នុងនាម ម.ជ.ម. ដែលបំពានប្រការ ៤០។ មោឃភាពនោះត្រូវមានអានុភាពប្រតិសកម្ម។ បុគ្គលរូបណាដែលបានធ្វើសកម្មភាពសម្រាប់ ម.ជ.ម. ដោយបំពានបញ្ញត្តិណាមួយនៃប្រការ ៤០ ត្រូវទទួលខុសត្រូវរួមគ្នា និងដោយឡែកចំពោះមុខ ម.ជ.ម. ចំពោះការខូចខាតណាមួយ និងទាំងអស់ដែល ម.ជ.ម. ទទួលរង។

៤០.៤. អគ្គលេខាធិការត្រូវធានាថាបញ្ញត្តិនានាក្នុងប្រការ ៤០ ត្រូវបានបោះពុម្ពផ្សាយ។

៤០.៥. ដើម្បីជៀសវាងការភ័ន្តច្រឡំ ប្រការ ៤០ នេះពាក់ព័ន្ធតែនឹងសមត្ថកិច្ចក្នុងការតំណាង និងការចងកាតព្វកិច្ចចំពោះ ម.ជ.ម. ជាមួយតតិយជនតែប៉ុណ្ណោះ ហើយមិនបានប៉ះពាល់ដល់សមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចណាមួយក្នុង ម.ជ.ម. ឡើយ។

## ជំពូកទី ១១

# ការិយបរិច្ឆេទ និងសវនកម្ម

### ប្រការ ៤១. ការិយបរិច្ឆេទ គម្រោងថវិកា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍គ្រប់គ្រងប្រចាំឆ្នាំ

៤១.១. ការិយបរិច្ឆេទរបស់ ម.ជ.ម. ត្រូវចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

៤១.២. ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវផ្ញើឯកសារខាងក្រោមទៅសមាជិក ម.ជ.ម. នីមួយៗ យ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន មុនបើកកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំ៖

(ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានធ្វើសវនកម្មឯករាជ្យ រួមបញ្ចូលទាំងរបាយការណ៍តុល្យការ របាយការណ៍ចំណូល និងចំណាយ ទិដ្ឋភាពមូលនិធិដែលបានសន្យាបានទទួល បានចំណាយ និងសមតុល្យរបស់មូលនិធិ របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍ស្ដីពីការប្រែប្រួលក្នុងមូលធន និងរបាយការណ៍ទិដ្ឋភាពនៃទ្រព្យអចលកម្មរបស់ ម.ជ.ម. ក្នុងការិយបរិច្ឆេទមុន

(ខ) របាយការណ៍របស់សវនករឯករាជ្យអំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

(គ) របាយការណ៍គ្រប់គ្រងប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ រួមមានការពិនិត្យដោយម៉ត់ចត់លើ ការអភិវឌ្ឍ និងព្រឹត្តិការណ៍ដែលប៉ះពាល់ដល់ ម.ជ.ម. ក្នុងឆ្នាំកន្លងមក និងការប្រមើលមើលសម្រាប់ឆ្នាំបន្ទាប់ និង

(ឃ) គម្រោងថវិកាប្រចាំឆ្នាំសម្រាប់ ម.ជ.ម. និងគម្រោងថវិកាសម្រាប់ត្រីមាសទីមួយនៃការិយបរិច្ឆេទបន្ទាប់។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍គ្រប់គ្រងប្រចាំឆ្នាំ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ។

កិច្ចប្រជុំមហាសន្និបាតត្រូវពិភាក្សាឯកសារដូចមានរៀបរាប់ខាងលើ និងត្រូវអនុម័តយល់ព្រមឯកសារទាំងនោះ ក្រោយពីមានការកែតម្រូវចាំបាច់នានា។

## ប្រការ ៤២. សវនកម្ម

៤២.១.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ជ.ម. នឹងត្រូវបានធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ។ មហាសន្និបាត ត្រូវតែងតាំងក្រុមហ៊ុនគណនេយ្យឯករាជ្យណាមួយដែលមានលក្ខណសម្បត្តិឱ្យទទួលបន្ទុកធ្វើសវនកម្ម។ ការតែងតាំងនេះអាចត្រូវបានបន្តសារជាថ្មីសម្រាប់រយៈពេលមួយឆ្នាំ។

៤២.២.សវនករឯករាជ្យត្រូវបង្ហាញរបាយការណ៍សវនកម្មរបស់ខ្លួនទៅមហាសន្និបាតនៅក្នុងកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំ។ ប្រធានអាចស្នើឱ្យសវនករធ្វើសវនកម្ម ឬការអង្កេតផ្សេងទៀត និងបង្ហាញរបាយការណ៍នោះទៅក្រុមប្រឹក្សាប្រតិបត្តិ។

៤២.៣.សមាជិកទាំងអស់នៃ ម.ជ.ម. និងអគ្គលេខាធិការដ្ឋានត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានាតាមការស្នើសុំរបស់សវនករ។

ជំពូកទី ១២

# អវសានប្បញ្ញត្តិ

## ប្រការ ៤៣. អវសានប្បញ្ញត្តិ

៤៣.១.បទបញ្ជាផ្ទៃក្នុងនេះត្រូវបំពេញបន្ថែម និងបង្កើតជាលិខិតតូបករណ៍រួមគ្នាជាមួយនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវស្របគ្នាជាមួយនឹងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀតដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

៤៣.២.បទបញ្ជាផ្ទៃក្នុងនេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវទុកជានិរាករណ៍។

៤៣.៣.បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ តទៅ។

ថ្ងៃអាទិត្យ ១៥ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**ប្រធាន**

NATIONAL COMMERCIAL ARBITRATION CENTRE

**ប៊ុន យូឌី**

WWW.NCAC.ORG.KH